# មជ្ឈមណ្ឌលឯកសារកម្ពុជា

PTI0082

## សម្ភាសន៍ជាមួយឈ្មោះ ទូច ឈុំ ភេទប្រុស អាយុ៦១ឆ្នាំ
## មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានអនុសេនាធំ
## ស្រុកកំណើតនៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
## សព្វថ្ងៃរស់នៅភូមិចំការជ្រៃត្បូង ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់
## ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១
## សម្ភាសន៍ដោយៈ ឡុង ដានី
## ០១:១១:៤៩
## ៣៦ទំព័រ

ដានី ៖ ជំរាបសួរលោកពូ ខ្ញុំចង់ស្គាល់ឈ្មោះលោកពូ ឈ្មោះពេញឈ្មោះអីដែរ?

ឈុំ ៖ បាទ! ខ្ញុំឈ្មោះ ទូច ឈុំៗ ។

ដានី ៖ ទូច ឈុំ ។ ពូអាយុប៉ុន្មានហើយ?

ឈុំ ៖ ខ្ញុំអាយុ៦១ហើយ ។

ដានី ៖ ពូរស់នៅភូមិអីដែរ សព្វថ្ងៃនេះ?

ឈុំ ៖ នេះភូមិចំការជ្រៃខាងត្បូង ។

ដានី ៖ ឃុំអីនឹង?

ឈុំ ៖ ឃុំអន្ទង់រាប ។

ដានី ៖ ស្រុកអីគេ?

ឈុំ ៖ ស្រុកវាលវែង ពោធិ៍សាត់ ។

ដានី ៖ គ្រួសារលោកពូ គាត់ឈ្មោះអីដែរ?

ឈុំ ៖ ជួន ថេន ។

ដានី ៖ ជួន ថេន គាត់អាយុប៉ុន្មានដែរ?

ឈុំ ៖ ៤៨ ។

ដានី ៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់?

ឈុំ ៖ ខ្ញុំកូន៨ ។

ដានី ៖ កូន៨នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឈុំ ៖ ស្រី៤ ប្រុស៤ ។

ដានី ៖ ស្រី៤ ប្រុស៤?

ឈុំ ៖ បាទ!

ដានី ៖ លោកតា ស្រុកកំណើតលោកតាទៅណាទៅ?

ឈុំ ៖ ខ្ញុំនៅអមលាំង ។

ដានី ៖ កំណើតភូមិអីគេ?

ឈុំ ៖ ភូមិទំនាប ។

ដានី ៖ ភូមិទំនាប?

ឈុំ ៖ បាទ!

ដានី ៖ ឃុំអី?

ឈុំ ៖ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

ដានី ៖ ឪពុកតា គាត់ឈ្មោះអី?

ឈុំ ៖ ស្លាប់អស់ហើយ ។

ដានី ៖ បាទ! ប៉ុនគាត់ឈ្មោះអី?

ឈុំ ៖ ញ៉ាំង សឿង ។

ដានី ៖ ញ៉ាំង សឿង?

ឈុំ ៖ បាទ!

ដានី ៖ គាត់ស្លាប់ពីអង្កាល់?

ឈុំ ៖ ស្លាប់នៅ២០០៣ ។

ដានី ៖ ចុះម្តាយ?

ឈុំ ៖ ម្តាយ ឆាយ ប៊ូ ។

ដានី ៖ ឆាយ ប៊ូ?

ឈុំ ៖ គាត់ស្លាប់យូរហើយតាំងពី១៩៦៦ ។

ដានី ៖ ចុះពូបងប្អូនបង្កើតប៉ុន្មាននាក់?

ឈុំ ៖ នៅសល់៤នាក់ ។

ដានី ៖ ទាំងអស់ប៉ុន្មាននាក់?

ឈុំ ៖ ៧នាក ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ឈុំ ៖ ស្រីតែ១ ក្រៅពីនឹងសុទ្ធប្រុស ។

ដានី ៖ ស្រីតែមួយ?

ឈុំ ៖ បាទ! ស្រីតែមួយ ។

ដានី ៖ ប្រុស៦នាក់ ។ លោកពូកូនទីប៉ុន្មាន?

ឈុំ ៖ ខ្ញុំកូនទី៣ ។

ដានី ៖ កាលពីក្មេងៗ ពូរៀនសូត្រនៅណាដែរ?

ឈុំ ៖ រៀននៅសាលាអមលាំងនឹង ។

ដានី ៖ រៀនសូត្រដល់ថ្នាក់ទីប៉ុន្មានដែរកាលនឹង?

ឈុំ ៖ អឺ! ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ។

ដានី ៖ នៅសាលាអមលាំង?

ឈុំ ៖ ហ្នឹង ។

ដានី ៖ ឈប់ឆ្នាំណាកាលនឹង?

ឈុំ ៖ អូ! យូរហើយតាំងពី៦៥នោះ ខ្ញុំឈប់ទៅរៀន ។

ដានី ៖ ឈប់រៀន តាំងពី៦៥?

ឈុំ ៖ បាទ! ៦៤ ៦៥ ។

ដានី ៖ ម៉េចបានឈប់រៀនតាំងពីឆ្នាំ៦៥?

ឈុំ ៖ មូលហេតុ ម្ដាយស្លាប់ទៅក៏យើងអត់នរណារកស៊ី យើងចិញ្ចឹមឪពុកម្ដាយ ប្អូនច្រើន ។ គិតទៅម្យ៉ាងយើងមានគោក្របីច្រើន ។ ចឹងពុកឲ្យខ្ញុំម្នាក់នឹងសម្រាប់មើលគោក្របី ចឹងការសិក្សានឹងក៏វារៀនផងមើលគោក្របីផង ដល់ម្ដាយស្លាប់ទៅឈប់តែម្ដងទៅ ។

ដានី ៖ ជួយមើលគោក្របីធ្វើស្រែរហូតដល់ឆ្នាំណា?

ឈុំ ៖ រហូតដល់បួស ។

ដានី ៖ បួសឆ្នាំណា?

ឈុំ ៖ ឆ្នាំមើល៦៧ហើយ ខ្ញុំបួស ។

ដានី ៖ បួសឆ្នាំ៦៧?

ឈុំ ៖ បាទ!

ដានី ៖ បួសបានប៉ុន្មានឆ្នាំ?

ឈុំ ៖ ខ្ញុំបួសបានម៉ាវស្សា ។

ដានី ៖ បួសនៅវត្តណា កាលនឹង?

ឈុំ ៖ នៅវត្តកន្សែងសំ ។

ដានី ៖ នៅវត្តកន្លែងសំៗនឹងនៅក្នុង?

ឈុំ ៖ ជាប់ភូមិទំនាប និងភូមិអមលាំងដែរ ជាប់ភូមិដែលខ្ញុំនៅនឹងណា ។

ដានី ៖ ចឹងបួសបានម៉ាឆ្នាំសឹកវិញ?

ឈុំ ៖ សឹកមកវិញមក ក៏មកនៅរកស៊ីធ្វើស្រែចំការ ចិញ្ចឹមបងប្អូន ។

ដានី ៖ អត់ទាន់មានប្រពន្ធ?

ឈុំ ៖ នៅទេ ។

ដានី ៖ ចឹងមករកស៊ីធ្វើស្រែ ធ្វើអីជាមួយឪពុកនឹង រហូតដល់ពេលណាទៀតទៅ?

ឈុំ ៖ បាទ! រហូតដល់រដ្ឋប្រហារ ។

ដានី ៖ ដល់រដ្ឋប្រហារឆ្នាំ៧០ ?

ឈុំ ៖ បាទ! ឆ្នាំ៧០នឹង យើងរដ្ឋប្រហារយូរតិចដែរណា ។

ដានី ៖ ដល់ពេលរដ្ឋប្រហារហើយម៉េចទៀតទៅ?

ឈុំ ៖ ខ្ញុំក៏ចូលមកនៅទ័ពឃុំ ឈ្លបឃុំ ។

ដានី ៖ មកនៅឈ្លបឃុំ?

ឈុំ ៖ បាទ! កាលនឹងវាមានចលនាខ្មែរក្រហមមក ។

ដានី ៖ កាលនឹងចូលឈ្លបឃុំនឹងលោកពូស្ម័គ្រចិត្តទេ ឬក៏មានការយ៉ាងម៉េច?

ឈុំ ៖ វាមានចលនាចឹងមក យើងចូលរួមចលនា ។

ដានី ៖ ចលនាយ៉ាងម៉េច ពូអាចរៀបរាប់?

ឈុំ ៖ អាគេធ្វើការឃោសនាអប់រំ ពេលនឹងថាលន់ នល់ ក្បត់ជាតិនោះ ធ្វើរដ្ឋប្រហារសម្តេចឪ ចឹងយើងក៏ចូលព្រៃមក តាមការឃោសនា ចូលនឹងក៏មិននៅភូមិដែរ ។

ដានី ៖ ចឹងកាលចូលឈ្លបឃុំនឹង ឃុំក៏នៅក្នុងព្រៃ មិនមែននៅក្នុង?

ឈុំ ៖ ហ៉េ! ឃុំដែរនៅនេះនឹង អូ! អាចូលដំបូងនឹងចូលក្នុងព្រៃ ។

ដានី ៖ ចឹងពេលដែលពូចេញពីផ្ទះដំបូងទៅនៅណា?

ឈុំ ៖ អានឹងខ្ញុំចេញពីផ្ទះដំបូងនៅនឹងភូមិយើងដែរ ឃុំអមលាំងនឹង ឈ្លបឃុំអានឹងគេរំដោះហើយ ។

ដានី ៖ ឈ្លបឃុំកាលនឹងចូលទៅគ្នាច្រើនទេ?

ឈុំ ៖ ហ៉េ! តាមម៉ាភូមិ២នាក់ ៣នាក់ៗតាមភូមិរួមគ្នាទៅ ម៉ាឃុំនឹងប្រហែលជា១០នាក់ ១១នាក់ ។

ដានី ៖ ចឹងកាលទៅឈ្លបឃុំពីណាគេ ទៅជាមួយ តាមពូចាំ?

ឈុំ ៖ កាលនឹងឈ្លបឃុំនឹង ខ្ញុំចូលដំបូងនឹងនៅជាមួយតាឆៃ ។

ដានី ៖ តាឆែនឹងគាត់ធ្វើអី?

ឈុំ ៖ ធ្វើឃុំ ។

ដានី ៖ ធ្វើគណៈឃុំ?

ឈុំ ៖ បាទ! គណៈឃុំ ។

ដានី ៖ គណៈឃុំអមលាំង?

ឈុំ ៖ អត់ទេ ឃុំព្រៃជ្រៅនោះ ។ តាមពិតតាគោលទេ ប្រធានឃុំនោះ ។

ដានី ៖ តាគល់?

ឈុំ ៖ គោល និងឆែនឹងហើយគេប្រធាន អនុប្រធាន ។

ដានី ៖ ចឹងកាលនឹងឈ្លបឃុំគ្នាច្រើនទេ?

ឈុំ ៖ អត់ទេ គ្នាប្រហែល១០-១១នាក់ គ្រាន់ដើរការពារនៅក្នុងឃុំ ។ តែខ្ញុំនៅបានប្រហែលជា ៤ខែប៉ុននឹងទេ ហើយបានស្រុកគេយកមកនៅកន្លែងស្រុកនេះវិញ ឲ្យខ្ញុំគ្រប់គ្រងទ័ពស្រុក ។

ដានី ៖ ស្រុកអីគេអានឹង?

ឈុំ ៖ ស្រុកជ្រាវ ឱរាល់ ។

ដានី ៖ អូ!កាលនឹងមានស្រុកជ្រាវ?

ឈុំ ៖ ស្រុកជ្រាវ ។

ដានី ៖ ជ្រាវ ឱរ៉ាល់ ។ មកនៅនឹងទ័ពស្រុកវិញ?

ឈុំ ៖ មកនៅទ័ពស្រុកនឹង ចឹងខាងស្រុកគេប្រមែលប្រមូលបានគ្នាប្រហែលជា៣០នាក់ ។ ហើយក៏បញ្ជូនទ័ពស្រុកនឹង មកឲ្យនៅផ្លូវជាតិលេខ៤ វៃផ្លូវជាតិលេខ៤ ។

ដានី ៖ កាលនឹងទ័ពស្រុកនឹង មកវៃនៅផ្លូវជាតិលេខ៤វិញ?

ឈុំ ៖ បាទ! មកនឹង ។ គ្រាន់ថ្ងៃណាមករួមផ្សំធ្វើសកម្មភាពឈ្លបនឹង មិនជាទ្រង់ទ្រាយធំអីទេ ។

ដានី ៖ នៅក្នុងឆ្នាំ៧០នឹងដែរ?

ឈុំ ៖ ឆ្នាំ៧១ ។

ដានី ៖ មកវៃអីនឹងរយៈពេលប៉ុន្មាន?

ឈុំ ៖ វៃ អឺ!គិតទៅខ្ញុំមកពីខែ៩ ខែ១១បានបញ្ចូលទ័ពស្រុកនឹងទៅទ័ពតំបន់វិញ ។

ដានី ៖ ចឹងកាលនៅទ័ពស្រុកគ្នា៣០នាក់ទេ?

ឈុំ ៖ ប្រហែល៣០នាក់ ។

ដានី ៖ ពីណាគេប្រធាន កាលនោះ?

ឈុំ ៖ ប្រធានទ័ពស្រុកនឹង?

ដានី ៖ បាទ! ទ័ពស្រុក ។

ឈុំ ៖ អានឹងគេឈ្មោះ អាយឿន ។

ដានី ៖ ឈ្មោះ យឿន ដល់ពេលខែ១១ ឆ្នាំ៧១នឹង ចូលមកទ័ពតំបន់?

ឈុំ ៖ មកទ័ពតំបន់ ។

ដានី ៖ តំបន់ប៉ុន្មានកាលនឹង?

ឈុំ ៖ តំបន់៣២ ។

ដានី ៖ ទ័ពតំបន់៣២?

ឈុំ ៖ បាទ!

ដានី ៖ ទ័ពតំបន់៣២ៗ គ្នាច្រើនទេ?

ឈុំ ៖ ច្រើន កងវរៈ៣០០នាក់ ។

ដានី ៖ ៣០០នាក់ដាង?

ឈុំ ៖ អឺ!

ដានី ៖ កាលនឹងតំបន់នៅណា កងទ័ពតំបន់?

ឈុំ ៖ ទ័ពតំបន់នឹង ឈរជើងនៅ ត្រង់ណាទេ ខ្ញុំភ្លេចហើយ វាយូរពេក នៅយើងម្តុំតាំងខ្សា ។

ដានី ៖ ពីណាគេប្រធានតំបន់?

ឈុំ ៖ តាឃឹម ។

ដានី ៖ តាឃឹម?

ឈុំ ៖ បាទ! អីឃឹមមិនដឹងទេ ខ្ញុំអត់ស្គាល់ ។

ដានី ៖ គាត់អ្នកស្រុកណាដែរ តាឃឹម?

ឈុំ ៖ អត់ស្គាល់ ។

ដានី ៖ ចុះដូចថាអនុៗគាត់អី?

ឈុំ ៖ ស្គាល់តែតាឃឹមនឹងមួយទេ ។

ដានី ៖ កាលនឹងពូមានតួនាទីអីដែរ?

ឈុំ ៖ ខ្ញុំអត់ទេ មេក្រុមគេ ។

ដានី ៖ ចឹងពូនៅទ័ពតំបន់នឹងតាំងពីឆ្នាំ៧១?

ឈុំ ៖ មើលនៅទ័ពតំបន់ បញ្ជូនមកទ័ពតំបន់នឹង មិនបានយូរប៉ុន្មានទេ វ៉ៃនេះក៏បញ្ជូនមកភូមិភាគ ទៀតមក ។

ដានី ៖ ខែណា ដល់ឆ្នាំណា?

ឈុំ ៖ អានឹង មើល ។

ដានី ៖ ខែ១១ ៧១ បានមកតំបន់?

ឈុំ ៖ បាទ! (ខែ) ១១ (ឆ្នាំ) ៧១ មកតំបន់ៗប៉ុន្មានខែទេ ប្រហែលជា២ខែ ៣ខែប៉ុននឹងបានឡើង មកភូមិភាគ ។

ដានី ៖ ដើមឆ្នាំ?

ឈុំ ៖ អត់ទេ ចុងឆ្នាំ ។

ដានី ៖ ចុងឆ្នាំ៧១?

ឈុំ ៖ បាទ! ចុងឆ្នាំ៧២ អឺ!ចុងឆ្នាំ៧១ ដើមឆ្នាំ៧២ ។

ដានី ៖ ដើម៧២ ចុង៧១នឹង ចូលមកភូមិភាគ ។ កាលនឹងភូមិភាគអីទៅ?

ឈុំ ៖ ភូមិភាគបស្ចិម ។

ដានី ៖ ចូលក្នុងភូមិភាគបស្ចិម?

ឈុំ ៖ បាទ! ភូមិភាគបស្ចិម ។

ដានី ៖ កាលនឹងដល់ពេលយើងមកភូមិភាគ យើងមានរៀបចំជាស្អីទៅ ជាកងពល ឬក៏ជា?

ឈុំ ៖ ជាកងពលតាមពិតទៅកាលនោះអត់ទាន់រៀបជាកងពលទេ នៅជាកងវរៈឯករាជ្យៗសុខៗខ្លួន ឡើយទេ ។ ដល់៧៣ ៧៤នេះ បានទៅជាមានកងពល សមរភូមិ ។

ដានី ៖ ចឹងកាលនឹងយើងនៅជាកងវរៈឯករាជ្យ មិនទាន់មានជាកងពលអីទេ?

ឈុំ ៖ បាទ!

ដានី ៖ គ្នាច្រើនទេ កាលជា?

ឈុំ ៖ កងវរៈហ៉េ! កាលនឹងច្រើនដែរ ខ្ញុំ ។ ប៉ុនចូលមកកងមជ្ឈិមនឹង ហើយក៏ខាងលើនឹងក៏ឲ្យកង វរៈមួយៗនឹង មកវ៉ៃយើងកំពតនេះ ផ្លូវជាតិលេខ៤នេះ ។ មកនឹងវាមាន៣កងវរៈ មាន ១៣១ ដែលខ្ញុំថា៣២តំបន់នឹងឡើងទៅកងមជ្ឈិមនឹងទៅជា១៣១វិញ ។ ដល់ពេលទៅវ៉ៃ លិចកំពតតាមផ្លូវជាតិលេខ៤នឹង មកនឹងវាមាន៣កង កង១៣១ កង១៧០ កង១៨០ ។

ដានី ៖ កាលនឹងពីណាអ្នកក្តាប់រួម?

ឈុំ ៖ កាលនឹងតាស្រស់ ។

ដានី ៖ តាស្រស់នឹង គាត់ប្រធានអីគេ?

ឈុំ ៖ ទេ! តាមពិតទៅ៣កងនឹង វាអត់បញ្ចូលគ្នាទៅជាសមរភូមិ អត់ចូលអីទេ ដោយឡែកៗ ។ តែគ្រាន់ថារៀបទៅ៣កងវរៈនឹងឲ្យតាស្រស់គាត់ទទួលរួម តែម្តងតាមខ្ញុំដឹង ។

ដានី ៖ តាស្រស់នឹង គាត់ទទួលរួមទាំង៣នឹង?

ឈុំ ៖ បាទ!

ដានី ៖ កងវរៈលេខប៉ុន្មានខ្លះ?

ឈុំ ៖ លេខ១៣១ ១៧០ ១៨០ ។

ដានី ៖ តាស្រស់ គាត់ទទួលរួម ។ ចុះប្រធានវរៈ១៣១ ពូស្គាល់ទេ?

ឈុំ ៖ ប្រធានវរៈ១៣១ កាលនោះមកពីហានណូយ ឈ្មោះអីមិនដឹងទេ ។

ដានី ៖ ចឹង១៧០?

ឈុំ ៖ ១៧០ ភ្លេចអស់ហើយ ព្រោះវាយូរដែរហើយ ។

ដានី ៖ ស្គាល់តាស្រស់នឹងគាត់នៅរួម?

ឈុំ ៖ បាទ! តាស្រស់ទទួលរួម ។

ដានី ៖ យើងវៃយើងអីរហូតដល់ពេលណាទៅ?

ឈុំ ៖ វៃរហូត អត់ទេឡើងទៅនឹងបានម៉ាឆ្នាំទេ ត្រឡប់មកវិញឆ្នាំ៧៣ ៧៤ ត្រឡប់មកវិញឆ្នាំ ៧៥ វៃចូលភ្នំពេញ ។

ដានី ៖ ដល់វៃទៅខាងនឹងតែម៉ាឆ្នាំទេ?

ឈុំ ៖ បាទ!

ដានី ៖ ចឹង៧៣យើងត្រឡប់មក?

ឈុំ ៖ អត់ទេ ទៅ៧៣ ។

ដានី ៖ ៧៣ទៅវៃនៅខាងកំពតនឹង?

ឈុំ ៖ បាទ! ខាងលិចកំពត ។

ដានី ៖ ដល់៧៤ត្រឡប់មកវិញ?

ឈុំ ៖ ៧៤ត្រឡប់មកវិញ ។

ដានី ៖ ៧៤ ត្រឡប់មកវៃនៅណា?

ឈុំ ៖ មកវៃនៅភ្នំពេញនឹង កំពុងវៃកំពង់ឆ្នាំងអីនឹង ។

ដានី ៖ កាលនឹងយើងឡើងជាកងពល?

ឈុំ ៖ អ្នកណា?

ដានី ៖ ដល់ពេល៧៤ ។

ឈុំ ៖ អ្នកណាឡើងកងពល?

ដានី ៖ អត់ទាន់ និយាយថា?

ឈុំ ៖ អត់ទេ អានឹងមកវៃ ដល់ត្រឡប់ពីនឹងមកវិញ បានបញ្ចូនគ្នាមានទៅជាកងពល ។

ដានី ៖ បញ្ចូលគ្នា?

ឈុំ ៖ បាទ! តែមិនមែនមកទាំងពាកងវរៈទេ មកតែកងវរៈ៣១នោះទេ ២កងវរៈនៅនឹងដដែល ។

ដានី ៖ ចឹងកាលនឹងពេលនោះ ពូត្រឡប់មកវិញដែរ?

ឈុំ ៖ បាទ!

ដានី ៖ ចឹងមកបញ្ចូលពេលវៃភ្នំពេញនឹង យ៉ាងម៉េចទៅចូលជាកងពលនឹង?

ឈុំ ៖ មកដល់ភ្នំពេញនឹង ចូលក្នុងកងពលទី១ ។

ដានី ៖ ចូលក្នុងកងពលទី១?

ឈុំ ៖ បាទ!

ដានី ៖ កងពលទី១ នៅកន្លែងណា?

ឈុំ ៖ នៅនឹងយើងវៃមិនទាន់នេះណា យើងវៃនៅក្រៅ ។ កងពលទី១កាលនឹង ទីបញ្ជាការដាក់ត្រង់ណាទេ វត្ត១ស្អីមិនដឹងទេ ហើយរៀបរយកម្លាំងវៃមកដើងមក មកកំពង់ឆ្នាំងមក មកខាងលិចលង្វែកនោះមក ទៅខត្តក្តនោះទៅ តាមមុខសញ្ញា ។

ដានី ៖ កាលនឹងកងពលទី១ពីណាគេអ្នក....?

ឈុំ ៖ តាម៉េតយើង ។

ដានី ៖ ស៊ូ ម៉េតនឹង?

ឈុំ ៖ បាទ!

ដានី ៖ តាម៉េត តាណាទៀត?

ឈុំ ៖ តាមពិតតាសឿងប្រធាន ។

ដានី ៖ តាសឿងប្រធាន តាម៉េត?

ឈុំ ៖ តាម៉េត អនុ ។

ដានី ៖ ចុះតាសាន ស្គាល់តាសាន តាប៉េង ហ៊ុច នឹង?

ឈុំ ៖ បាទ! អូតាសាន ។

ដានី ៖ តាសានគាត់ស្អីគេ?

ឈុំ ៖ គាត់សមាជិក ។

ដានី ៖ គាត់ក្នុងគណៈកងពលដែរ?

ឈុំ ៖ បាទ!

ដានី ៖ តាសាននឹង កាលនឹងគេហៅគាត់តាម៉េច?

ឈុំ ៖ ហ៊ើ! ខ្ញុំស្គាល់តែឈ្មោះ តាសាននឹងម៉ង ។

ដានី ៖ ចឹងគេហៅតាសានដែរ?

ឈុំ ៖ បាទ!

ដានី ៖ ប៉ុន្តែមិញ លោកពូហៅតាសានម៉េច?

ឈុំ ៖ អូ! អានឹងគេចេះហៅក្រៅទេ តាសានប៉េងហ៊ុច ។

ដានី ៖ តាសានប៉េងហ៊ុច ហៅពីអន្លាល់?

ឈុំ ៖ ហៅយើងក្រោយៗមកនឹងណា តាមពិតមុនឈ្មោះគាត់ចឹង ។

ដានី ៖ ឈ្មោះតាសានចឹង?

ឈុំ ៖ បាទ!

ដានី ៖ ចឹងគណៈកងពលទី១នឹង មានតាសៀង តាម៉េត ហើយនឹងតាសាន?

ឈុំ ៖ បាទ! អូ!នៅមួយទៀត ។

ដានី ៖ មួយទៀតពីណាគេ?

ឈុំ ៖ បងល្វៃមួយទៀត ។

ដានី ៖ តាល្វៃមួយទៀត?

ឈុំ ៖ តាល្វៃ ហើយតាសាន ក៏គាត់ជាទីប្រឹក្សា ។

ដានី ៖ ៣នាក់នឹងក្នុងម៉ាកងពលទី១?

ឈុំ ៖ បាទ ។

ដានី ៖ ចុះពូកាលនឹងមានតួនាទី?

ឈុំ ៖ ខ្ញុំអនុសេនាធំ ។

ដានី ៖ កាលនោះពូអនុសេនាធំ?

ឈុំ ៖ បាទ!

ដានី ៖ អនុសេនាធំពូនៅក្នុងវរៈណា?

ឈុំ ៖ នៅក្នុងវរៈ១៣១ ។

ដានី ៖ នៅវរៈ៣១ដដែល ។ វរៈសេនាធំលេខប៉ុន្មានកាលនឹង?

ឈុំ ៖ ៣០៦ ។

ដានី ៖ ពីណាគេប្រធានវរៈសេនាធំ៣០៦?

ឈុំ ៖ អត់ទេ វរៈសេនាធំអី អនុសេនាធំ ដែលខ្ញុំនេះនឹង ។

ដានី ៖ ៣០៦ វរៈ១៣១នឹងវរៈសេនាតូច?

ឈុំ ៖ វរសេនាតូច ។

ដានី ៖ ចុះវរសេនាធំ?

ឈុំ ៖ វរសេនាធំនឹង វរៈសេនាធំលេខប៉ុន្មានទេកាលនឹង វរៈសេនាធំ៥២ ។

ដានី ៖ បាទ! អត់ចាំទេ?

ឈុំ ៖ បាទ! វាភ្លេចហើយ ។

ដានី ៖ ចឹងកាលនឹងកងពលយើងវ៉ៃមកខាងកំពង់ឆ្នាំង ខាងលង្វែក ខាងខត្តុគ្គអីវិញ?

ឈុំ ៖ បាទ!

ដានី ៖ ចឹងអត់វ៉ៃចូលភ្នំពេញទេ?

ឈុំ ៖ អានឹងវ៉ៃសារចុះ សារឡើង បានទាល់៧៥នឹង បានវ៉ៃចូលទៅភ្នំពេញម៉ង ។ នៅនេះយើងវ៉ៃ ពី៧៤ ។

ដានី ៖ វ៉ៃ៧៤ ដល់៧៥វ៉ៃយ៉ាងម៉េច?

ឈុំ ៖ ៧៥វ៉ៃចូលភ្នំពេញ វ៉ៃ ។

ដានី ៖ វ៉ៃពីកន្លែងណាមក?

ឈុំ ៖ មុខសញ្ញាយើង ឯណាចូលទៅចំបាសិតនឹង ។

ដានី ៖ ចំបាសិតនឹង?

ឈុំ ៖ បាសិត កំពង់ធំ តែមិនមែនម៉ាកងនឹងទេ វា ។

ដានី ៖ ចុះខាងបាសិត ខាងកំពង់ធំ ក្រែងកងពលខាងពួកខត្តរគេវ៉ៃតាមនឹងដែរ?

ឈុំ ៖ បាទ! ពួកខត្តរក៏វ៉ៃទៅជាប់គ្នាទៅប្រឡោះនឹងដែរ ចាប់ដៃគ្នាទៅ ។

ដានី ៖ ចាប់ដៃគ្នាទៅ?

ឈុំ ៖ បាទ!

ដានី ៖ ចឹងដល់ពេលចូលភ្នំពេញចូលតាមមុខព្រួញណា ដល់ពេលយើងចូលវ៉ៃបែក?

ឈុំ ៖ ចូលដល់ចំក៉ាសំរោង ។

ដានី ៖ ចូលចំក៉ាសំរោង?

ឈុំ ៖ បាទ!

ដានី ៖ បត់ទៅដល់ភ្នំពេញ?

ឈុំ ៖ ក៉ាសំរោងទៅដល់ភ្នំពេញ ចំពោធិ៍ចិនតុងនឹងម៉ង ខាងលិចចំ អាស្ថានីយ៍ អឺ!ផ្លូវបំបែក ។

ដានី ៖ ពូអាចរៀបថា ពេលដែលយើងវ៉ៃកាលនឹង យើងប្រើយុត្តិសាស្ត្រអីយ៉ាងម៉េចខ្លះទៅ?

ឈុំ ៖ អូ! យុត្តិសាស្ត្រកាលនឹងមានតែថាយើងវ៉ៃ រំកិលខ្សែត្រៀមចូលមក ។

ដានី ៖ រំកិលខ្សែត្រៀមចូល?

ឈុំ ៖ បាទ! រំកិល ដូច្នេះយើងវៃបែកចឹងទៅ ដូចថាយើងវៃទៅដល់វ៉ាសំរោង ទាហានមិនទប់នៅវ៉ាសំរោង ដល់វៃវ៉ាសំរោងបែកចឹងទៅ១ភ្នំពេញ មកពោធិ៍ចិនតុងទៀត បានយើងឡើងទៅទៀត បែកល្ងាចនឹងឡើងល្ងាចនឹង ។ ឡើងខ្សែត្រៀមទៅដឹកខ្សែត្រៀមនឹង អាថ្ងៃ១៥នឹងបុកមកយើងត្រៀមគំលាតប្រហែលជា១គីឡូកន្លះពីផ្លូវជាតិ ។

ដានី ៖ ចុះកាលនឹង យើងមានសម្ភារៈ ដូចជាអាវុធគ្រាប់អី យើងមានគ្រប់គ្រាន់ដែរ?

ឈុំ ៖ គ្រប់គ្រាន់ដែរ ។

ដានី ៖ គ្រាប់បានមកពីណា?

ឈុំ ៖ ឃើញអាកា គ្រាប់បេ គ្រាប់អី ។

ដានី ៖ ចុះរថក្រោះអីយើងមានដែរអត់?

ឈុំ ៖ រថក្រោះកាលនឹងយើងមាននេះតិច នោះតិច រថក្រោះដែលយើងយកបាន ។

ដានី ៖ រថក្រោះដែលយើងយកបានពីរបស់ទាហាន?

ឈុំ ៖ របស់ទាហាន តិច ចឹងយើងប្រើកាំភ្លើងធំច្រើន ម៉ាកងមានដេកា ៧៥ម៉ាដើង ៨២ម៉ាដើម ហើយគួបផ្សំកាំភ្លើង ។

ដានី ៖ កាលនឹង ពេលដែលពូវៃចូលភ្នំពេញ នៅជាវរៈសេនាតូច?

ឈុំ ៖ អត់មានទេ អនុសេនាធំរហូត ។

ដានី ៖ កាលនឹងពូនៅសមរភូមិម៉ង?

ឈុំ ៖ នៅសមរភូមិ ។

ដានី ៖ នៅក្នុងប្រយុទ្ធ តទល់?

ឈុំ ៖ បាទ! តទល់ ។

ដានី ៖ ចុះកាលនឹង ពូមានត្រូវរបួស ត្រូវអីទេ?

ឈុំ ៖ ត្រូវដែរ ត្រូវ៣សារ កាលទៅវៃកោះកុងនោះ អឺ!ទៅវៃខាងលិចកំពតនោះត្រូវម៉ាសារ ។

ដានី ៖ ត្រូវកន្លែងណា?

ឈុំ ៖ កាលទៅវៃនៅកំពតនេះ ត្រូវជើងនេះ ត្រឹមនេះ ហើយនឹងត្រគៀក ។

ដានី ៖ អូ! អានឹងត្រូវអំបែង?

ឈុំ ៖ ៣កន្លែង អំបែង ។

ដានី ៖ សម្រាកពេទ្យ?

ឈុំ ៖ សម្រាកពេទ្យម៉ាខែជាង ។

ដានី ៖ ត្រូវមីនៗយ៉ាងម៉េច អានឹងមីន?

ឈុំ ៖ មីនរបស់ទាហានដាក់ ។

ដានី ៖ ទាហានដាក់ យើងដាន់?

ឈុំ ៖ អត់ទេ ដើរទាក់ ។ ខ្ញុំមិនទាក់ទេ ពេលទាហានយើងវៃបែកហើយ យើងលើកដៃហើយ វា ស្រែកថាក្មេងក៏ឲ្យយកដែរ បេ៤០មក ខ្ញុំឈរលើថ្នល់ មិនគេដាក់ចិញ្ចើមថ្នល់ណា ក្មេងរត់ មកទាក់មកផ្ទុះអត់អី វាត្រូវតែខ្ញុំ ។

ដានី ៖ ចុះដល់ពេលត្រូវលើកទី២?

ឈុំ ៖ ត្រូវលើកទី២ វៃចូលភ្នំពេញ អឺ!វៃសាលាលេខ៥ ។

ដានី ៖ ត្រូវអីអានឹង?

ឈុំ ៖ អានឹងក៏ត្រូវមីនដែរ ។

ដានី ៖ ត្រូវចំណា?

ឈុំ ៖ ត្រូវចំត្រគៀកដែរ ។

ដានី ៖ ដេកនឹង ដេកពេទ្យយូរទេ?

ឈុំ ៖ អានឹងដេកពេទ្យយូរដែរ ត្រគៀកនឹង ប្រហែលជាម៉ាខែ ជាងម៉ាខែ កន្ទះ ត្រូវត្រគៀកផង ត្រូវថ្ពវផង ។

ដានី ៖ ដេកពេទ្យនៅណា?

ឈុំ ៖ នេះដេកពេទ្យនៅយើង ខាងណាទេខាងជើងតាំងពោធិ៍ តាំងក្រសាំង ។

ដានី ៖ ពេទ្យនឹង ពេទ្យរបស់មជ្ឈិម?

ឈុំ ៖ បាទ! ពេទ្យរបស់មជ្ឈិម ។

ដានី ៖ ពេទ្យរបស់តាជួន ជឿន?

ឈុំ ៖ បាទៗ ។

ដានី ៖ តាជួន ជឿន មានមកព្យាបាលផ្ទាល់?

ឈុំ ៖ អត់ទេ អត់ផ្ទាល់ បុគ្គលិកប្រុស ។

ដានី ៖ ប៉ុន្តែពេទ្យនឹង ពេទ្យរបស់តាជួន ជឿន?

ឈុំ ៖ បាទ! បណ្តាញខាងលើរៀបចំ ។

ដានី ៖ ចុះលើកទី៣ របួសនៅណា?

ឈុំ ៖ លើកទី៣ ខ្ញុំរបួសពេលដែលខ្ញុំវៃយួន ។

ដានី ៖ ដល់ពេលយើងវៃចូលនឹង ពេលដែលយើងបើកសមរភូមិវៃចូលភ្នំពេញរយៈពេលប៉ុន្មាន យើងវៃបានបែក?

ឈុំ ៖ ហេ៎! ច្រើនលើកច្រើនសារ ។ វៃចឹងទៅ គេវៃគេរុញ យើងដកចឹងមក ។ ម៉ាខែ កន្លះខែ រៀបចំវៃចូលទៀត ប្រទាញប្រទុងគ្នាទៅវិញទៅមក ការវៃសមរភូមិក្ដៅគគុក ។

ដានី ៖ វៃប្រទាញប្រទុងយូរដែរ?

ឈុំ ៖ បាទ! ចុះកាំភ្លើងធំ ពីក្នុងតំរៀបកាប៉ាល់ ថ្មើរជើងក៏ថ្មើរជើង សមរភូមិកប់ស្រូវ បាសិត កំពង់ធំនឹង វាជាសមរភូមិវាល ចឹងកាបាល់ហោះមកពីលើថ្ងៃឡើង នៅក្នុងត្រង់សេរអត់មាន ចេញ សំងំត្រង់សេរ១ដាក់ក្អែងភេទ ។

ដានី ៖ ចឹងស៊ិតស្វាញដែរ មុននឹងចូលដល់ភ្នំពេញ?

ឈុំ ៖ បាទ! ស៊ិតស្វាញដែរនឹង ទម្រាំចូលដល់មិនមែនស្រួល ។

ដានី ៖ ចឹងដែលពូចូលមកមុនដំបូងចូលតាមមុខព្រួញនៅពោធិ៍ចិនតុង?

ឈុំ ៖ ខ្ញុំចូលពោធិ៍ចិនតុង ។

ដានី ៖ ចូលទៅឃើញយ៉ាងម៉េចដែរ ដំបូងដែលយើងចូលដល់ពោធិ៍ចិនតុង?

ឈុំ ៖ ចូលទៅឡើងជាន់ផ្លូវជាតិបណ្ដោយមានអី គ្រាន់យើងចូលទៅ ប្រជាជនចេញពីទីភ្នំពេញ បណ្ដើរ១ ... ។

ដានី ៖ ចេញមកបណ្ដើរ១?

ឈុំ ៖ តាំងថ្ងៃ១៦ ចេញប្រៀប ថ្ងៃ១៧ចេញប្រៀប ។

ដានី ៖ ចឹងដល់ពេលយើងចូលដល់ភ្នំពេញ កងពលរបស់ពូនៅកន្លែងណា?

ឈុំ ៖ ការពារពោធិ៍ចិនតុង ឆ្លងដែន ។

ដានី ៖ អត់មានចូលដល់ជ្រៅទៀត?

ឈុំ ៖ បាទ! អត់ចូលដល់ជ្រៅទេ ។

ដានី ៖ ត្រឹមពោធិ៍ចិនតុង?

ឈុំ ៖ ការពារពោធិ៍ចិនតុង កងវរៈមួយលិច កងវរៈមួយនៅប៉ុស្តិ៍វិទ្យុចឹងទៅ កងវរៈមួយទៀតនៅ ចោមចៅ កងវរៈមួយទៀតមកនៅខាងជើងពោធិ៍ចិនតុង ៣កងវរៈនឹង ។

ដានី ៖ ចឹងពេលបែកភ្នំពេញហើយ ពូនៅភ្នំពេញរហូត?

ឈុំ ៖ អត់ទេ ខ្ញុំនៅមើល យើងបែក៧៥ ៧៦ ៧៧ខ្ញុំមកនៅកំពង់ឆ្នាំងវិញហើយ ខ្ញុំនៅបានម៉ាឆ្នាំ ជាងតិច មកនៅភ្នំពេញ ។

ដានី ៖ ពេលដែលបែកភ្នំពេញហើយយ៉ាងម៉េចទៅ ដល់ពេលកងពលទីនឹងនៅដដែល ឬក៏មានការ ប្រែប្រួល?

ឈុំ ៖ នៅដដែល អត់មានអីខុស ។

ដានី ៖ អត់មានផ្លាស់ប្តូរអី?

ឈុំ ៖ បាទ! អត់មានផ្លាស់ប្តូរអី ។

ដានី ៖ នៅកងពលទី១ដដែល?

ឈុំ ៖ បាទ! នៅកងពលទី១ដដែល មើលបាទ! អូហ្នឹងហើយផ្លាស់ បែកភ្នំពេញហើយ យើងចូលភ្នំពេញហើយ បែកភ្នំពេញហើយបានបែកកងពលនឹង ។ តាសឿង គាត់មកសមុទ្រនេះមកបានតាម៉េតនឹង គាត់ទទួលកងពល៥០២វិញ ។

ដានី ៖ តាម៉េត គាត់កាន់៥០២?

ឈុំ ៖ ៥០២ ។

ដានី ៖ តាម៉េតកាន់៥០២ តាសឿង?

ឈុំ ៖ តាសឿងគាត់នៅកងពលទី១ ១ដដែល ។ កាលនោះកងពលតាសឿងនឹងដូចថាមកខាងសមុទ្រនោះទេ ។

ដានី ៖ ចុះផ្សេងទៀត ដូចតាល្វៃ ដូចតាសាន?

ឈុំ ៖ បងនោះនៅជាមួយបងសឿង ។

ដានី ៖ តាណា?

ឈុំ ៖ អឺ! នៅជាមួយបងម៉េតនឹង ។

ដានី ៖ ពីណាគេ?

ឈុំ ៖ បងល្វៃ បងសាន ។

ដានី ៖ តាល្វៃមកនៅជាមួយតាម៉េត?

ឈុំ ៖ បាទ! នៅៗបែកភ្នំពេញហើយនៅទាំងអស់គ្នា ជុំគ្នានឹង ។ សាននឹងកាលនឹងគាត់វរៈសេនាធំទេ កាលពីនៅវៃនោះ ។ វរៈសេនាធំតែរហូតនឹង ខ្ញុំភ្លេចបងសាននេះចេញ មិនមែនកងពលទេ បងសានវរៈសេនាធំ ។

ដានី ៖ ចឹងកាលនឹងតាម៉េតគាត់ទៅ៥០២?

ឈុំ ៖ បាទ!

ដានី ៖ តាសឿង នៅកងពលទី១ដដែល?

ឈុំ ៖ បាទ! មកកងពលទី១ ។

ដានី ៖ តាល្វៃមកនៅជាមួយតាម៉េត?

ឈុំ ៖ បាទ!

ដានី ៖ ៥០២?

ឈុំ ៖ បាទ! ៥០២ ។

ដានី ៖ ហើយតាសឿននៅកងពលទី១?

ឈុំ ៖ បាទ!

ដានី ៖ ចុះតាសាន គាត់នៅខាងណា?

ឈុំ ៖ បងសាន គាត់នៅវរៈសេនាធំ១ជាមួយ ។

ដានី ៖ វរៈសេនាធំ ជាមួយតាសឿន ឬ ជាមួយតាសាន?

ឈុំ ៖ អត់ទេ ជាមួយបងឆនវិញ ឆន សេង, យើងមេឃុំនឹងណា៎ ។

ដានី ៖ ឆន គាត់នៅណានឹង?

ឈុំ ៖ នៅកងពលទី១ នឹងដែរ វរៈសេនាធំ ។

ដានី ៖ នៅវរសេនាធំ កងពលទី១ដដែល?

ឈុំ ៖ បាទ! អឺ!៥០២ ម៉េតនៅពោធិ៍ចិនតុង ។

ដានី ៖ ចុះពូមកនៅណាវិញ?

ឈុំ ៖ ខ្ញុំនៅជាមួយនឹងដែរ ។

ដានី ៖ នៅជាមួយនៅ៥០២ដែរ?

ឈុំ ៖ ៥០២ដដែល ។

ដានី ៖ មកនៅ៥០២ជាមួយតាម៉េតដែរ?

ឈុំ ៖ បាទ!

ដានី ៖ ចឹងពេលបែកភ្នំពេញហើយចឹង កងពល៥០២នៅម្តុំណាទៅ?

ឈុំ ៖ នៅពោធិ៍ចិនតុង ។

ដានី ៖ ចុះពូនៅពោធិ៍ចិនតុងដែរ?

ឈុំ ៖ ខ្ញុំនៅពោធិ៍ចិនតុង តែគ្រាន់នៅ៧៧គេឲ្យមកកំពង់ឆ្នាំងនេះវិញ ធ្វើព្រលានថ្មី ។

ដានី ៖ ចឹងនៅពោធិ៍ចិនតុង កាលនឹងពូយ៉ាងម៉េច ពូអាចរៀបរាប់ពេលដែលយើងបែកហើយគេបែងបែកកងពលផ្សេង ដូចជាតាម៉េតមក៥០២ តាសឿននៅកងពលទី១មកខាងណាវិញ?

ឈុំ ៖ កាលនោះខ្ញុំវាមិនច្បាស់ ដូចខាងសមុទ្រ ។

ដានី ៖ មកខាងសមុទ្រ បើនៅ៥០២នៅពោធិ៍ចិនតុងទាំងអស់?

ឈុំ ៖ បាទ! ៥០២នៅពោធិ៍ចិនតុង ។

ដានី ៖ កាលនឹងយើងកងពលទី២ យើងបំបែកជា២?

ឈុំ ៖ បាទ! បំបែក ។

ដានី ៖ បំបែកហើយមានចូលខាងថ្មី?

ឈុំ ៖ បំបែកហើយយកពីខាងភាគពិសេស កណ្ដាលស៊ីងមកចូលកង៥១ ៥២ វរៈសេនាធំ បង្កើតជាកងពល៥០២ ។

ដានី ៖ ៥០២?

ឈុំ ៖ បាទ! ព្រោះដកទៅនោះម៉ាកងវរៈទៅ ម៉េតគាត់យកជាប់ ។

ដានី ៖ យកតែម៉ាវរៈទេ?

ឈុំ ៖ ចឹងចូល៥១ ៥២ បានពាកងវរៈនឹងទៅជាកងពល ។

ដានី ៖ វរៈសេនាធំ?

ឈុំ ៖ បាទ! វរៈសេនាធំ ។

ដានី ៖ ចឹងគាត់ដកមកម៉ាវរៈសេនាធំទេ?

ឈុំ ៖ វរៈសេនាធំ ។

ដានី ៖ ដកមកម៉ាវរៈសេនាធំទេ ហើយ២វរៈសេនាធំទៀត?

ឈុំ ៖ ២វរៈសេនាធំទៀត ខាងភូមិភាគពិសេស បញ្ចូលមកនឹង ទៅជាម៉ាកងពល៥០២ ។

ដានី ៖ កាលនឹងពូជាអ្នកទទួលបន្ទុកផ្នែកអី?

ឈុំ ៖ ខ្ញុំនៅជាអនុសេនាធំដដែល ។

ដានី ៖ អនុសេនាធំនៅម្ដុំណា?

ឈុំ ៖ ខ្ញុំនៅខាងជើងពោធិ៍ចិនតុង ។

ដានី ៖ ខាងណា?

ឈុំ ៖ ទំនប់តាំងក្រសាំង ។

ដានី ៖ ទំនប់តាំងក្រសាំង?

ឈុំ ៖ បាទ!

ដានី ៖ នៅខាងនោះធ្វើអីទៅ?

ឈុំ ៖ ហ៊ើ! អត់មានធ្វើអីទេ ធ្វើស្រែៗកងទ័ពកាលនោះ ។

ដានី ៖ ចឹងកងទ័ពជើងអាកាសកាលនឹងយើង?

ឈុំ ៖ អត់ទេ បេះបង់ៗ កងទ័ពជើងអាកាសផ្សេង ចឹងពួកខ្ញុំនេះកងទ័ពការពារព្រលានទេ ។

ដានី ៖ ៥០២ ការពារព្រលាន?

ឈុំ ៖ បាទ! ការពារព្រលានៗ ក្នុង៥០២ មានកងអាកាស កងផ្សេងចឹងណា ពាកងនឹងគឺសម្រាប់ការពារទេ ។

ដានី ៖ ពាក់ងអីគេ?

ឈុំ ៖ ពាក់ងវរៈនឹងណា សម្រាប់ការពារទេ ។

ដានី ៖ ទ័ពអាកាសគេផ្សេងទៀត?

ឈុំ ៖ ទ័ពអាកាសគេផ្សេងទៀត ។

ដានី ៖ ប៉ុន្តែទ័ពអាកាសនឹងក្នុងកងពល៥០២ដែរ?

ឈុំ ៖ ៥០២ដែរ ។

ដានី ៖ ក្រោមតាម៉េតគ្រប់គ្រងដែរ?

ឈុំ ៖ បាទ!

ដានី ៖ ចុះពូនៅការពារធ្វើស្រែនឹងរហូត?

ឈុំ ៖ ការពារៗជួយធ្វើស្រែប្រជាជន មកធ្វើនៅអន្លង់ស្នួល មកធ្វើនៅទំនប់កប់ស្រូវ លើកទំនប់ លើកប្រឡាយជាមួយប្រជាជននឹង ។

ដានី ៖ ចឹងពូនៅវរៈណា វរៈលេខប៉ុន្មាន?

ឈុំ ៖ ខ្ញុំនៅវរៈ៣១ដដែល ។

ដានី ៖ នៅវរៈ៣២ វរសេនាធំលេខប៉ុន្មាន?

ឈុំ ៖ វរសេនាធំប៉ុន្មានទេ លេខកាលនោះ ។

ដានី ៖ ពីណាគេប្រធានវរៈសេនាធំ?

ឈុំ ៖ កាលនឹងប្រធានវរសេនាធំបង ឆន ។

ដានី ៖ ឆន សេង ប្រធានឃុំយើងអន្លង់រាបនេះនឹង?

ឈុំ ៖ បាទៗ ។

ដានី ៖ កាលនឹងគាត់ប្រធានវរៈសេនាធំ?

ឈុំ ៖ ប្រធាន អនុប្រធានបងពន្ទក ។

ដានី ៖ អនុប្រធាន?

ឈុំ ៖ បងពន្ទក អភិបាលរងស្រុក ។

ដានី ៖ ហ្នឹងអនុប្រធាន?

ឈុំ ៖ បាទ!

ដានី ៖ បើតាម៉េតគាត់?

ឈុំ ៖ គាត់កងពលហើយ ។

ដានី ៖ តាល្វៃ?

ឈុំ ៖ តាល្វៃអនុ ។

ដានី ៖ ពីណាគេសមាជិក?

ឈុំ ៖ សមាជិក បងម៉េត បងល្វៃ អូ!ក្រោយមកចូលបងឆន គាត់ឡើងទៅជាសមាជិកកងពល នឹង ។

ដានី ៖ ឆន សេង?

ឈុំ ៖ បាទ! ឆន សេង ។

ដានី ៖ ចឹងពូនៅនឹងធ្វើតែស្រែ?

ឈុំ ៖ ខ្ញុំធ្វើស្រែ ជួយធ្វើស្រែផង ការពារផង បែកកម្លាំងគ្នាយើង ឧទាហរណ៍ថាម៉ាអនុសេនាធំ ចេញចឹងទៅ ទៅធ្វើស្រែម៉ាអនុសេនាធំខ្ញុំទៅជួយធ្វើស្រែប្រជាជន ២អនុសេនាធំនៅការពារ នឹងខ្ញុំម៉ាកងវរៈវាមាន៣អនុសេនាធំ ។ ដូរគ្នាទៅកន្លះខែម្នាក់ចឹងទៅ វិលមកការពារក្រុងចឹង ទៅ ។

ដានី ៖ ចឹងពូធ្លាប់បានចូលទៅទីក្រុងភ្នំពេញទេ?

ឈុំ ៖ ចូលតើ គ្រាន់យើងចូលទៅលេងម៉ាភ្លែតៗ ។

ដានី ៖ ចូលទៅលេង?

ឈុំ ៖ បាទ!

ដានី ៖ ចូលទៅលេងជាមួយពីណាគេ?

ឈុំ ៖ មានការចាំបាច់អី ចូលទៅម៉ាភ្លែតចឹងទៅ ចេញទៅ ។

ដានី ៖ យើងចូលទៅលេងទេ?

ឈុំ ៖ បាទ!

ដានី ៖ ទៅលេងអត់អីទេ គេអត់មានថាអី?

ឈុំ ៖ អត់មានអី ។ គេសួរគេនាំដែរ គ្រាន់និយាយចេះ អឺ!ចង់ទៅមើលប៉ុស្ដិ៍វិទ្យុស៊ីងមានជ័យ ចឹង យើងទៅតាមផ្លូវខាងលិចពេទ្យលោកសង្ឃចឹងទៅ ផ្សារដើមគរចឹងទៅ យើងចេញទៅត្បូង ទៅ វិលមកម៉ាជុំអូរបែកក្អមម៉ាជុំនឹង ចូលកន្លែងយើងទៅ ។

ដានី ៖ ជិះអីទៅ?

ឈុំ ៖ ម៉ូតូ ។

ដានី ៖ មានគេយាមគេអីដែរ កាលនឹង?

ឈុំ ៖ យាម តែគ្រាន់អ្នកស្គាល់គ្នា ។

ដានី ៖ ស្គាល់គ្នា?

ឈុំ ៖ បាទ!

ដានី ៖ ចឹងពេលប្រជុំពេលអីទៅប្រជុំនៅណា?

ឈុំ ៖ ប្រជុំនៅតាមអគ្គភាព កងពល ។

ដានី ៖ អគ្គភាពកងពល?

ឈុំ ៖ បាទ!

ដានី ៖ ចុះពូមានធ្លាប់ដែលទៅប្រជុំនៅស្ពាត?

ឈុំ ៖ ស្ពាត យើងថាម៉ាឆ្នាំម្ដងអីទៅ ។

ដានី ៖ ម៉ាឆ្នាំម្ដង ។ ប្រជុំនៅស្ពាតប្រជុំជាមួយពីណាខ្លះ?

ឈុំ ៖ ប្រជុំជាមួយនែក! ខៀវ សំផន, នួន ជា, ។

ដានី ៖ គេប្រជុំរៀនពីអីអានឹង?

ឈុំ ៖ ហ្នឹងថា ចង់ភ្លេចអស់ព្រោះសំខាន់និយាយពីការកសាងប្រទេស ។

ដានី ៖ ខៀវ សំផន, នួន ជា, ពីណាទៀត?

ឈុំ ៖ ប៉ុល ពត, ខៀវ សំផន, នួន ជា, គណៈអចិន្ត្រៃយ៍គាត់នឹង ។

ដានី ៖ ចុះសុន សេនអី?

ឈុំ ៖ សុន សេន ។

ដានី ៖ សុន សេនដែរ?

ឈុំ ៖ បាទ!

ដានី ៖ សុន សេន គាត់ធ្វើអីកាលនឹង?

ឈុំ ៖ ផ្នែកខាងលើខ្ញុំអត់សូវដឹងទេ បង មិនដឹងថាខាងណាធ្វើអីៗ ។ អត់ទេព្រោះយើងដឹកនាំខាងក្រោម វាដឹងតែរឿងចង្អុលឲ្យយើងធ្វើអីហើយ បើថាឲ្យជួយធ្វើស្រែប្រជាជនៗ ។

ដានី ៖ កាលនឹងឲ្យជួយធ្វើស្រែប្រជាជន?

ឈុំ ៖ ជួយធ្វើស្រែប្រជាជន ។

ដានី ៖ កាលនឹងយើងហូបចុកអីម៉េច?

ឈុំ ៖ កងទ័ពកាលនឹងហូបដូចប្រជាជនដែរ ។ ប្រជាជនបបរ យើងបបរដែរ កងទ័ពធ្វើម៉េចខុសពីប្រជាជន ។

ដានី ៖ ហូបឆ្អែត?

ឈុំ ៖ អូ! អារឿងឆ្អែត មិនងាយទេ បើថាឲ្យឆ្អែតមិនងាយទេ បើថាឲ្យឆ្អែតមិនឆ្អែតទេ ។ តែមិនដឹងធ្វើម៉េច ចុះបើប្រជាជនក៏ចឹង យើងក៏ចឹងទៅហើយ អ្នកណាហ៊ានដេញដោលអីគេខ្លាច ។

ដានី ៖ ខ្លាចអីគេ?

ឈុំ ៖ ចេះតែខ្លាច ។

ដានី ៖ ចុះខ្លាចអីយើងកងទ័ព?

ឈុំ ៖ បាទ! កងទ័ពក៏ ។

ដានី ៖ យើងកងទ័ព យើងអ្នកវៃរំដោះបាន?

ឈុំ ៖ យើងអ្នវៃ ប៉ុន្តែចេះតែខ្លាចទៅ ។

ដានី ៖ ខ្លាចពីណាគេ មានហេតុផលអីបានយើងខ្លាច?

ឈុំ ៖ វាមានហេតុផល កាលនឹង ការចាប់ដាក់គុក ការវៃអីវាមានខ្លះៗដែរ ដល់ចឹងចេះតែគិតដែរ ។ ប៉ុនសម្រាប់ខ្ញុំអត់ទេ មិនដែលខាងលើចាប់ ឬមួយក៏វៃដំប្រំធាក់អីអត់ទេ ។

ដានី ៖ បើអ្នកផ្សេងមាន?

ឈុំ ៖ អ្នកផ្សេងឃើញមានខ្លះៗ ។

ដានី ៖ ម៉េចបានគេចាប់គេវៃនឹងមកមូលហេតុអី?

ឈុំ ៖ ទេ! អានឹងវាចំណោទត្រង់ថាចោទថាក្បត់អីចេះចុះ ។

ដានី ៖ ចោទថាក្បត់ គេចាប់យកទៅណា?

ឈុំ ៖ អូ! មិនដឹងចាប់ទៅណាទេ ខ្ញុំជំនាន់នោះអត់សូវដឹងទេ ព្រោះយើងនៅមេក្រោមៗ ។

ដានី ៖ ចុះកាលនឹង ពូដែលឮគុកទួលស្លែងអីដែរ?

ឈុំ ៖ គុកទួលស្លែងដែលឮ តែគ្រាន់យើងមិនដែលដើរ ។ កាលនឹងអត់ស្គាល់ផង ឮតែឈ្មោះ ។

ដានី ៖ ឮឈ្មោះថាម៉េច?

ឈុំ ៖ ឈ្មោះថាគុកទួលស្លែង ។ ហើយគុកទួលស្លែងឮតាំងពីសង្គមមក ។

ដានី ៖ ដែលឮឈ្មោះឌុចទេ?

ឈុំ ៖ ឌុច ខ្ញុំទើបមកឮនឹងនេះទេ ព្រោះមិនដែលស្គាល់គ្នាផង ។

ដានី ៖ កាលជំនាន់ពូនៅពោធិ៍ចិនតុងអីមិនដែលឮទេ?

ឈុំ ៖ បាទ! អត់ដែលឮទេ ។ និយាយរួមទៅនៅពោធិ៍ចិនតុងនឹង មើល៧៨បញ្ជូនខ្ញុំឲ្យទៅព្រំដែនយួន ។ ចឹងបានទៅ៧៦ ៧៧ ។

ដានី ៖ ៧៦ ៧៧ ដល់ពេល៧៧នៅណា?

ឈុំ ៖ ៧៨បញ្ជូនខ្ញុំទៅព្រំដែន ។

ដានី ៖ ចុះពូមានប្រសាសន៍មិញថា មានមកកំពង់ឆ្នាំងដែរ?

ឈុំ ៖ អូ! អានឹងមកតាំងពី៧៧ ។

ដានី ៖ ៧៧ ពូយ៉ាងម៉េច ពូឈប់នៅពោធិ៍ចិនតុងហើយ?

ឈុំ ៖ ទេ! មេឲ្យខ្ញុំមកធ្វើព្រលានកំពង់ឆ្នាំង ជួយធ្វើព្រលាន។

ដានី ៖ ឆ្នាំ៧៧ ខែប៉ុន្មាន ពូចាំ?

ឈុំ ៖ មកកាលឆ្នាំ ខែ៩ ។

ដានី ៖ ពាក់កណ្ដាលឆ្នាំហើយ?

ឈុំ ៖ បាទ!

ដានី ៖ កាលនឹងយ៉ាងម៉េចបានយើងផ្លាស់ពីពោធិ៍ចិនតុង មកខាង?

ឈុំ ៖ ឲ្យមកធ្វើព្រលាន ប្រមូលកម្លាំងឲ្យមកធ្វើព្រលាន។

ដានី ៖ កាលនឹងប្រមូលកម្លាំងឲ្យមកធ្វើព្រលាន មកគ្នាច្រើន?

ឈុំ ៖ ច្រើន មកគ្នាច្រើន មកធ្វើព្រលានកំពង់ឆ្នាំង។

ដានី ៖ មកប្រហែលប៉ុន្មានទៅ?

ឈុំ ៖ មកឃើញជុំគ្នាច្រើន នៅធ្វើព្រលានកំពង់ឆ្នាំង តាមពិតមកដកតែខ្ញុំ២-៣នាក់ទេ។

ដានី ៖ ពីណាអ្នកបញ្ជាឲ្យដកពូ ឲ្យមកធ្វើ?

ឈុំ ៖ អានឹងកងវរៈគេឲ្យមក ។

ដានី ៖ កងវរៈណា?

ឈុំ ៖ ប៊ុត ។

ដានី ៖ ប៊ុត វរៈសេនាតូច?

ឈុំ ៖ វរៈសេនាតូច ។

ដានី ៖ ដកពូមកព្រលាន។ ចឹងព្រលានយន្តហោះនឹងរបស់កងពល៥០២ដែរ?

ឈុំ ៖ កងពល៥០២ ។

ដានី ៖ ធ្វើយ៉ាងម៉េច ពូអាចជួបជម្រាបប្រាប់ខ្ញុំ?

ឈុំ ៖ មកធ្វើព្រលាន មកផ្លាស់ដី រើសស្មៅឲ្យស្អាត ហើយនឹងបានឡានដឹកថ្មដឹកអីទៅឲ្យក្រាល ហើយអាឡូបង្ហាប់កុំឲ្យវាស្រុតនឹង បានគេចាក់បេតុង។

ដានី ៖ ចឹងពូព្រលាននឹង តាំងពីព្រលាននឹងចាប់ផ្ដើមធ្វើដំបូង?

ឈុំ ៖ អត់ទេ ដកខ្ញុំទៅកណ្ដាលឆ្នាំ។ ប៉ុនចុងឆ្នាំដកខ្ញុំមកវិញ ឲ្យខ្ញុំទៅព្រំដែន៧៨ ខែ១១ ។

ដានី ៖ ចឹងដំបូងនឹង?

ឈុំ ៖ ៧៧ ពាក់កណ្ដាល៧៨ បានដកខ្ញុំទៅព្រំដែន ៧៩ ។

ដានី ៖ ៧៧នឹង ដកពូទៅព្រលានយន្តហោះកំពង់ឆ្នាំង?

ឈុំ ៖ បាទ!

ដានី ៖ កាលនៅពេលានយន្តហោះកំពង់ឆ្នាំងនឹង គេធ្វើយ៉ាងម៉េច តាមពូដឹង ពេលានយន្តហោះនឹង គេធ្វើយ៉ាងម៉េច ទំហំអីប៉ុនណា ប៉ុនពេលានយន្តហោះពោធិ៍ចិនតុង ឬក៏ខុសពីពោធិ៍ចិនតុង?

ឈុំ ៖ ដូចថាធំជាង ។

ដានី ៖ សម្រាប់អីអានឹង?

ឈុំ ៖ ដើម្បីយើងសម្រាប់កាប៉ាល់ហោះចំបាំង ។

ដានី ៖ សម្រាប់កាប៉ាល់ហោះចំបាំង?

ឈុំ ៖ បាទ!

ដានី ៖ ថាធំជាង ពីណាអ្នកមកធ្វើ?

ឈុំ ៖ ហ៎! ខ្ញុំអត់សូវដឹងទេ រឿងបច្ចេកទេស ។

ដានី ៖ អត់ដឹង?

ឈុំ ៖ អត់ដឹង ។

ដានី ៖ ប៉ុន្តែគ្នាច្រើនអត់ ធ្វើនឹង?

ឈុំ ៖ គ្នាច្រើន ។

ដានី ៖ ប្រហែលប៉ុន្មានទៅ?

ឈុំ ៖ អូ! ចូលម៉ឺននាក់ ។

ដានី ៖ អ្នកដែលធ្វើនឹងច្រើន មកពីណាខ្លះ?

ឈុំ ៖ ចំរុះ ដកកងទ័ពពីមុខមកផង ពីណាពីណែមកផង ។

ដានី ៖ សុទ្ធតែកងពល៥០២ទាំងអស់ ឬក៏មានកងពលផ្សេង?

ឈុំ ៖ អត់ទេ កងពលផ្សេងមួយទៀត ។

ដានី ៖ កងពលណាខ្លះទៅ?

ឈុំ ៖ ច្រើនណាស់ ។ ខ្ញុំកាលនឹង បើយើងអត់សូវស្គាល់កងពលសព្វដែរ ។

ដានី ៖ មកពីភូមិភាគណាខ្លះ?

ឈុំ ៖ មកច្រើន ខាងបូព៌ាឃើញមក ពីខាងបស្ចឹមក៏នៅនឹង គេយកពីភ្នំពេញ ។ កម្លាំងច្រើនណាស់ កាលនឹងមកពីគ្រប់កងពល ។

ដានី ៖ គ្រប់កងពល មកពីបូព៌ាក៏មក?

ឈុំ ៖ បាទ!

ដានី ៖ ច្រើនតែពួកអ្នកដែលមកពីភូមិភាគផ្សេងៗជាកងទ័ពដែរ ឬក៏ពួករបៀបថាយើងមាន?

ឈុំ ៖ កង់ទ័ព ។

ដានី ៖ ដូចថាពួកនឹងមានសមាសភាពអីគេ?

ឈុំ ៖ សមាសភាព ។ បាទ! ចឹងហើយដកពីមុខមក មានបញ្ហាចឹង បានគេដកមកចឹង បើគ្មានមិនដកទេ ។

ដានី ៖ ចុះពូ ដែលគេដកទៅនៅកំពង់ឆ្នាំង ពូសមាសភាពដែរ ឬអត់?

ឈុំ ៖ មិនដឹងយ៉ាងម៉េច ខ្ញុំរយៈមកក្រោយអស់បងប្អូនច្រើនដែរ បងប្អូនជំនាន់នឹងធ្វើទាហាន ជំនាន់សម្តេចនឹង ទាំងពូទាំងបងប្អូន ។

ដានី ៖ ប៉ុន្តែ គេមកធ្វើព្រលាននឹង គេឲ្យពូមកគ្រប់គ្រងគេ?

ឈុំ ៖ អត់ទេ មិនគ្រប់គ្រងទេ មកធ្វើ ។

ដានី ៖ មកធ្វើ?

ឈុំ ៖ បាទ! ធ្វើដូចបងប្អូនចឹងដែរ ។

ដានី ៖ មិនមែនឲ្យយើងមក?

ឈុំ ៖ អូ! មិនមែនឲ្យយើងមកគ្រប់គ្រងណា ។

ដានី ៖ មកមើលខុសត្រូវទេ?

ឈុំ ៖ បាទ! អត់ទេ ។

ដានី ៖ តែពូនៅតែឋានៈអនុសេនាធំដដែល?

ឈុំ ៖ អនុសេនាធំ តែគ្រាន់ដកមក បើយើងគ្មានកូនទាហាន គ្មានអី អត់មានផង ។

ដានី ៖ ក្រែងគេឲ្យមក?

ឈុំ ៖ ខ្ញុំមកតែ៣-៤នាក់នឹង ។

ដានី ៖ មិនមែនមកគ្រប់គ្រងទេ?

ឈុំ ៖ អត់ទេ ។

ដានី ៖ ចុះពីណាគេមកគ្រប់គ្រងនៅព្រលាន?

ឈុំ ៖ អូ! មិនដឹងអ្នកណាៗទេ កាលនឹងវាច្រើនដែរ កម្លាំងវាច្រើន ។

ដានី ៖ មេធំជាងគេ?

ឈុំ ៖ មេធំមានតែអាម៉េតនឹងហើយ ។

ដានី ៖ គាត់មកកំពង់ឆ្នាំងដែរ?

ឈុំ ៖ នឹង ចេញចូលៗ ។

ដានី ៖ ចេញចូលៗ?

ឈុំ ៖ បាទ!

ដានី ៖ ចុះតាល្មៃ?

ឈុំ ៖ មើលកាលនោះ មើលដូចបងល្មៃដែរមក កំពង់ឆ្នាំង តែគ្រាន់ចេញចូលៗ ។

ដានី ៖ គ្រាន់ចេញចូល?

ឈុំ ៖ បាទ!

ដានី ៖ ចុះមកព្រលានយន្តហោះកំពង់ឆ្នាំងនឹងយ៉ាងម៉េចទៅ ដូចថាយើងធ្វើការងារហូបចុកអី ដូចកាលពូនៅពោធិ៍ចិនតុងដែរ ឬខុសគ្នា?

ឈុំ ៖ ខុសគ្នា មកកំពង់ឆ្នាំង យើងអត់បាយ ព្រោះពលកម្មធ្វើការងាររាល់ថ្ងៃ ទាំងថ្ងៃទាំងយប់ ។ បើងបានហូបបាយ ។ ហើយខ្ញុំមើលមិនទាន់បានហូបបាយផង ។

ដានី ៖ តែធ្វើការហត់?

ឈុំ ៖ ធ្វើហត់ ។

ដានី ៖ ធ្វើការធ្ងន់ជាងនៅ?

ឈុំ ៖ ធ្វើចេះ ធ្វើទាំងថ្ងៃ ទាំងយប់ ។

ដានី ៖ ធ្វើរួច?

ឈុំ ៖ អ្នកខ្លះៗដូចជំនាញធ្វើព្រលានទៅ កងខ្លះទៀតធ្វើផ្លូវពីនេះទៅ ។ ធ្វើផ្លូវក៏កាប់ជជុះដីឲ្យស្មើដូចគ្នា ។

ដានី ៖ ធ្វើទាំងថ្ងៃទាំងយប់?

ឈុំ ៖ ធ្វើឲ្យស្អាត ធ្វើពីក្រាំងស្គារបន្តូរមក អានឹងគម្រោងការធ្វើដាក់អាត្រយោលប្រេង ពីរ៉ាវទេះភ្លើងចូលមក ។

ដានី ៖ ធ្វើពីក្រាំងស្គារមក?

ឈុំ ៖ បាទ! ពីក្រាំងស្គារ ។

ដានី ៖ ធ្វើបន្តមក បូមប្រេងចូលមកម៉ង?

ឈុំ ៖ បញ្ចូលមកព្រលាន តែធ្វើមិនទាន់ហើយ ។ តែធ្វើមិនទាន់ហើយផង ក៏ត្រូវដកខ្ញុំទៅព្រំដែន ។

ដានី ៖ ដកឆ្នាំណា?

ឈុំ ៖ ដកឆ្នាំចុង៧៨ ។

ដានី ៖ ចុង៧៨ ម៉េចបានដកទៅ?

ឈុំ ៖ ដឹងអី បើសមរភូមិវៀតណាមវ៉ៃ ចូលមកក៏ដកឲ្យទៅជួយទប់ ។

ដានី ៖ បើងពីណាគេអ្នកដកពូទៅ?

ឈុំ ៖ កងពលនឹងហើយ អ្នកដក ។

ដានី ៖ ពីណាគេ?

ឈុំ ៖ តាម៉េតនឹង ។

ដានី ៖ តាម៉េតអ្នកដក?

ឈុំ ៖ បាទ!

ដានី ៖ ដកទៅណា ដកពូទៅណា?

ឈុំ ៖ ដកខ្ញុំមកពោធិ៍ចិនតុង ឡើងយន្តហោះទៅចុះក្រចេះ ទៅតាមផ្លូវជាតិលេខ៧ ទៅស្នួល ទៅជប់ ។

ដានី ៖ គ្នាច្រើនអត់ទៅនឹង?

ឈុំ ៖ ទៅនឹងក្នុងនោះ៧នាក់ តែគ្រាន់កងនឹងវាទៅមុន២សារហើយ បានដកខ្ញុំទៅបន្ថែម ។

ដានី ៖ ដកទៅបន្ថែម ដូចថាពូទៅបញ្ជាទ័ព?

ឈុំ ៖ បាទ! ទៅដល់បានកន្លះខែ វៀតណាមវ៉ៃចូលព្រល ។

ដានី ៖ ទៅដល់នឹង យើងទៅនៅសមរភូមិ យើងទៅបញ្ជាវិញ?

ឈុំ ៖ បាទ!

ដានី ៖ ពូឡើងអីវិញ?

ឈុំ ៖ ទៅដល់នឹងវរៈសេនាតូច ។

ដានី ៖ ឡើងវរៈសេនាតូច?

ឈុំ ៖ បានកន្លះខែ យួនវ៉ៃចូល យើងមកក្រោយ ។

ដានី ៖ វ៉ៃនៅម្តុំណា?

ឈុំ ៖ វ៉ៃនៅចំការកៅស៊ូ ជប់ ។

ដានី ៖ ចឹងនៅជប់ ខាងស្នួង ខាងមេមត់ ទៅខាងអីនឹងវិញ?

ឈុំ ៖ បាទ! ទៅខាងនឹងវិញ តែគ្រាន់ខ្ញុំទៅកន្លះខែ បានទៅដល់ចំការកៅស៊ូនឹង គេវ៉ៃចូលមកទៀតមក យើងចេះតែថយៗរហូត ទប់តែ២សារយើងអត់ឈ្នះ គេមកមុខមក យើងរត់តាមពីក្រោយគេមក ។

ដានី ៖ កាលនឹងពូមានគ្រួសារនៅ?

ឈុំ ៖ ខ្ញុំនៅ ។

ដានី ៖ អត់ទាន់មានទេ?

ឈុំ ៖ អូ! មានហើយៗ មានតាំងពីខ្ញុំនៅពោធិ៍ចិនតុង ។

ដានី ៖ នៅពោធិ៍ចិនតុង?

ឈុំ ៖ បាទ! ៧៧ ។

ដានី ៖ ៧៧មានហើយ?

ឈុំ ៖ បាទ!

ដានី ៖ ពូរៀបការជាមួយមីង១ដដែល?

ឈុំ ៖ នារីកាត់ដេរ អត់ទេ ។

ដានី ៖ មុន ។ ចឹងពូរៀបគ្រួសារមុនម៉ាសារហើយ?

ឈុំ ៖ បាទ! ម៉ាសារ ។

ដានី ៖ កាលនឹងឈ្មោះអី?

ឈុំ ៖ ឈ្មោះរុន ។

ដានី ៖ គាត់ធ្វើអី?

ឈុំ ៖ កាត់ដេរ ។

ដានី ៖ កាត់ដេរនៅណា?

ឈុំ ៖ កាត់ដេរ កងទ័ពកាត់ដេរ ។

ដានី ៖ របស់កងពលដែរ?

ឈុំ ៖ របស់កងពល ។

ដានី ៖ គាត់អ្នកស្រុកណា?

ឈុំ ៖ នៅស្អាង ។

ដានី ៖ ស្អាងកោះធំ ។ ចុះរៀបការហើយ បាននៅជាមួយគ្នា?

ឈុំ ៖ ចឹង គេនៅកន្លែងគេ យើងនៅកន្លែង យើងធ្វើម៉េចយើងខ្វាច ។

ដានី ៖ មានកូនទេ?

ឈុំ ៖ ខ្ញុំបានកូនមួយ ។ កូនស្លាប់ជំនាន់៧៩ ខ្ញុំបាត់គ្នារគាត់រសាយរហូត ។

ដានី ៖ ចុះពេលដែលពូទៅកំពង់ឆ្នាំងអី គាត់ទៅជាមួយអត់?

ឈុំ ៖ អត់ទេ ។

ដានី ៖ នោពោធិ៍ចិនតុង ពូទៅកំពង់ឆ្នាំងតែឯង?

ឈុំ ៖ បាទ!

ដានី ៖ តែខស្សាហ៍បានឡើងមកជួបគ្នា?

ឈុំ ៖ អត់ទេ ខ្ញុំមិនដែលបានទេ .....(ស្តាប់មិនបាន) ។

ដានី ៖ គាត់ទៅវិញ?

ឈុំ ៖ បាទ! គាត់ទៅវិញ ។

ដានី ៖ រយៈពេលប៉ុន្មាន គាត់ទៅម្តង?

ឈុំ ៖ ទេ! ម៉ាខែទៅ២ថ្ងៃ៣ថ្ងៃ ។

ដានី ៖ ដល់ពេលពូទៅពោធិ៍ចិនតុងវិញ មកព្រំដែន?

ឈុំ ៖ ខ្ញុំមកតែម៉ាយប់មកកំពង់ឆ្នាំង ម៉ាយប់គេយកកាប៉ាល់ហោះដឹកទៅ ។

ដានី ៖ បានជួបគាត់ទេ?

ឈុំ ៖ បានជួបៗម៉ាយប់នឹង ទៅហើយបែកគ្នា ។

ដានី ៖ ហើយបែកគ្នារហូត?

ឈុំ ៖ បាទ!

ដានី ៖ អត់ដែលឃើញគាត់ទេ?

ឈុំ ៖ អត់ ។ ហើយដល់ពេលសមាហរណកម្មហើយ ខ្ញុំតែស្តូឲ្យគេរកៗមិនឃើញ ខ្វះគេមិននៅ មិនដឹងនៅណា តាមចាស់ ។

ដានី ៖ ចុះអត់មានទៅរកគាត់នៅស្រុកកំនើត?

ឈុំ ៖ ទៅរកៗអត់ឃើញ ។

ដានី ៖ ស្គាល់ស្រុកកំណើតគាត់ដែរ?

ឈុំ ៖ អត់ច្បាស់លាស់ ខាងនឹង ព្រោះគេចល័តចេញពីភូមិផ្ទះគាត់ ។

ដានី ៖ បានន័យថាគាត់កើតជានៅភូមិឃុំស្រុកអី?

ឈុំ ៖ ដឹង តែដល់ទៅរកៗវាមិនឃើញ ។

ដានី ៖ អត់ស្គាល់ឈ្មោះឪពុកម្តាយគាត់ទេ?

ឈុំ ៖ ឪពុកម្តាយស្លាប់អស់ ។

ដានី ៖ បងប្អូនបង្កើត?

ឈុំ ៖ បងប្អូន កាលនឹងបងប្អូនមានតែ៣នាក់ កាលនឹងបងប្អូនគេធ្វើគណៈឃុំអីផង ចឹងបាត់អស់ស្រមោល ។

ដានី ៖ បានន័យថាបើសិនជាពូចង់ទៅរកគាត់ ទៅសួរស្រុកកំណើតរបស់គាត់ កំណើតដែលគាត់ដាក់ថាកើត ។ ទៅដល់នឹងសួររកឈ្មោះឪពុកម្តាយ ។

ឈុំ ៖ ចេះប្អូន ស្រុកកំណើតខ្ញុំអត់ដាក់លាក់ទេ កាលនឹងគាត់ចល័តដែរ ចឹងគេបានគ្នាមកអាការសួរគេប្រាប់តែគាត់រស់នៅកន្លែងថ្មីៗ ដល់ពេលនេះឃួនចូលមក បែកគ្នា ដល់ពេលយើងទៅសួរ

អាកន្ទែងថ្មីនឹង មិនដឹងអាកំណើតស្រុកកំណើតចាស់គាត់មិនដឹងនៅណា ។ តែដល់សួរអ្នកស្រុកអ្នកភូមិនឹងដូចថាគេថាអត់ស្គាល់ ។

ដានី : សួររកឈ្មោះឪពុកម្ដាយគាត់?

ឈុំ : បាទ! ហ្នឹងហើយ សួររកឪពុកម្ដាយ មិនស្គាល់ សួររកឈ្មោះប្រពន្ធខ្ញុំទៀត វាអត់ស្គាល់ មិនដឹងជាវានៅណា ។

ដានី : ចឹងពេលដែលយើងទៅវៃនេះនឹង ពេលពូទៅដល់ដប់ ស្វងនឹង យើងទៅដល់នឹងបានត្រឹមនឹងក៏ដកមក?

ឈុំ : បាទ! ត្រឹមនឹង ។

ដានី : ដកមកយ៉ាងម៉េចទៀតទៅ?

ឈុំ : ដកមកដើរខាងជើងរហូត ខាងកំពង់ធំ សៀមរាប ។

ដានី : ខាងកំពង់ធំ សៀមរាប មកខាងភូមិភាគកណ្ដាលវិញ?

ឈុំ : បាទ! ខាងកំពង់ធំ សៀមរាបមក មកវៃនៅព្រំប្រទល់សៀមរាបកំពង់ធំ ទៅនៅដងរែក ។

ដានី : ជួបកែ ពកអត់?

ឈុំ : ជួប តែគ្រាន់គាត់មុខសញ្ញាផ្សេង ។

ដានី : មុខសញ្ញាផ្សេង?

ឈុំ : បាទ!

ដានី : អត់នៅជាមួយគាត់ទេ?

ឈុំ : អត់ទេ ។

ដានី : ពូនៅជាមួយពីណា?

ឈុំ : កាលនឹងនៅជាមួយ ហឿង១កងពល ។

ដានី : ហឿង កងពល?

ឈុំ : បាទ! ឥឡូវគេនៅឧត្ដមសេនីយ៍ ។

ដានី : ឈ្មោះអីគេ គាត់ឈ្មោះហឿង?

ឈុំ : អីហឿងទេ អត់ចាំឈ្មោះ ចាំតែតានឹង ។

ដានី : វៃហើយយ៉ាងម៉េចទៀត ចេញពីនេះ?

ឈុំ : អាពេលនេះខ្ញុំចេញមក កាលនឹងតាគាត់ឲ្យនៅឆ្នាំ៨៨នៅកំពង់ឆ្នាំង នៅស្រុកកំណើតវិញ មានមេទ័ពមួយកងពលស្រុកកំណើតនៅកំពង់ឆ្នាំង ។ ចឹងតាត្រូវឲ្យមេទ័ពនឹង មកធ្វើការនៅកំពង់ឆ្នាំង កំពង់ស្ពឺវិញ ។ ចឹងគាត់ក៏ដឹងថា ខ្ញុំនៅនឹង ក៏យកខ្ញុំមកវិញ មកជាមួយគាត់មក ។

ដានី ៈ តាណា?

ឈុំ ៈ តាម៉ុកនឹង ។

ដានី ៈ តាម៉ុកឲ្យពូមកនៅខាងកំពង់ឆ្នាំង?

ឈុំ ៈ តាមពិតមេកងពលនឹងទេ គាត់សុំតា គាត់ស្លាប់បាត់ហើយឈ្មោះ តាស៊ីន ។

ដានី ៈ តាស៊ីននឹង សុំពូចេញពីណា?

ឈុំ ៈ ខ្ញុំនៅវៃព្រាំដែននឹង ។

ដានី ៈ វៃព្រាំដែនខាងណា?

ឈុំ ៈ វៃកងហៀងនឹង នៅវៃព្រាំដែនយើងខាងលិចព្រះវិហារនឹង ១០០៣នឹង ។ នៅវៃនឹង ដល់ពេលតាគាត់ឲ្យឈ្មោះ ស៊ីន នឹង កងពលនឹងមកធ្វើការនៅកំពង់ឆ្នាំងកំពង់ស្ពឺ ។ បងស៊ីន នឹង ដឹងថាខ្ញុំនៅកំពង់ស្ពឺ ក៏គាត់សុំតាៗក៏ឲ្យមកជាមួយគាត់មក ។

ដានី ៈ ឆ្នាំណា ចុងឆ្នាំ៧៨?

ឈុំ ៈ ចុងឆ្នាំ៧៨ ។

ដានី ៈ ចឹងកាលនឹងពូមកជាមួយគាត់?

ឈុំ ៈ អត់មានអីទេ ខ្ញុំអត់មាននាទីអីទេ មកនៅជាជាប់នឹងគាត់ដោយសារថា ភ្នំឱរ៉ាល់គឺខ្ញុំស្គាល់ក្រឡោះក្រលាត ចឹងគាត់យកខ្ញុំមកនៅជាមួយគាត់នឹង គ្រាន់តែជួយមានសភាពការណ៍អីយើងចល័ត ។

ដានី ៈ ចុះកាលពូទៅវៃព្រាំដែន ពូវរៈសេនាតូច?

ឈុំ ៈ បាទ! វរៈសេនាតូច ។

ដានី ៈ ហើយដល់ក្រោយមកទៀត?

ឈុំ ៈ ក្រោយមកទៀត ជាប់ជាមួយគាត់នៅសមរភូមិ ។

ដានី ៈ ប៉ុន្តែជាមួយហៀងនឹង ក៏ពូនៅវរៈសេនាតូចដែរ?

ឈុំ ៈ បាទ! វរសេនាតូចដែរ ។

ដានី ៈ ប៉ុន្តែដល់មកនៅជាមួយតាស៊ី?

ឈុំ ៈ អត់មានធ្វើអីទេ ។

ដានី ៈ មកនៅអែបគាត់?

ឈុំ ៈ មកនៅមន្ទីរគាត់ អែបគាត់នឹង យើងនាំសភាពការណ៍ យួនវាតតាតយើងដឹងល្បាតភ្នំឱរ៉ាល់នឹង ចេះតែនាំចេញទៅ ។

ដានី ៈ ប៉ុន្តែ ពូក្រែងធំជាងវរៈសេនាតូចទៀត?

ឈុំ ៖ អត់ទេ អត់មាននាទីផង ។

ដានី ៖ និរសា?

ឈុំ ៖ មិននិរសាទេ គ្រាន់ជំនួយការជួយៗនាយអោយគាត់ ។

ដានី ៖ មកនៅខាងកំពង់ស្ពឺ ខាងភ្នំឪរ៉ាល់នឹង?

ឈុំ ៖ បាទ! ភ្នំឪរ៉ាល់នឹង ។

ដានី ៖ ចុះក្រែងកែវ ពង្ស គាត់នៅស្រុកនឹងដែរ?

ឈុំ ៖ កែវ ពង្ស គាត់វរៈសេនាតូច គាត់នៅធ្វើការពីមុន តាំងពីមុនមកហើយ ដល់ចឹងមកដកគាត់ ពីនោះមក មកទទួលលើកែវ ពង្សនេះទៅទៀត ។

ដានី ៖ តាស៊ុននឹង មកទទួលលើកកែវ ពង្សទៀត?

ឈុំ ៖ បាទ! ទទួលលើកែវ ពង្សទៅទៀត ។

ដានី ៖ ធំជាង កែវ ពង្ស នឹងទៀត?

ឈុំ ៖ បាទ! ធំជាង កែវ ពង្សនឹងទៀត ។

ដានី ៖ កែវ ពង្សនឹង នៅកងពលរបស់គាត់ដែរ?

ឈុំ ៖ នៅកងពលនឹងដែរ ។

ដានី ៖ កងពលលេខប៉ុន្មាន?

ឈុំ ៖ កាលនឹងសមរភូមិ១៤ គាត់សមរភូមិ១៤ ។

ដានី ៖ កែវ ពង្សគាត់?

ឈុំ ៖ កែវ ពង្ស គាត់នៅវរៈសេនាតូច ។

ដានី ៖ ចុះតាស៊ីន គាត់ស្លាប់ឆ្នាំណា?

ឈុំ ៖ គាត់ស្លាប់ឆ្នាំ៩៨ ។

ដានី ៖ ៩៨?

ឈុំ ៖ បាទ! បន្ទាប់ពី...(ស្តាប់មិនបានសម្លេងម៉ាស៊ីនរំខាន) ។ អន្លង់វែងនឹងដែរ ។

ដានី ៖ ស្លាប់ដោយសារអី?

ឈុំ ៖ តាស៊ីន....(ស្តាប់មិនបានសម្លេងម៉ាស៊ីនរំខាន) ។

ដានី ៖ តាស៊ីន នៅអន្លង់វែង?

ឈុំ ៖ បាទ! ។

ដានី ៖ គាត់ចាស់ហើយម៉េច?

ឈុំ ៖ ហ៉ើ! ជម្ងឺពាច........ ។

ដានី ៖ គាត់ចំណាស់ អាយុប៉ុន្មាន?

ឈុំ ៖ កាលនឹងអាយុ៥០ជាង ក្រែង៥៥ ៥៧ដឹង។

ដានី ៖ ចុះកាលពូនៅឪរ៉ាល់នៅអី ដែលពូឈ្មោះតាសាន?

ឈុំ ៖ សាន ពូ ខ្ញុំមកនឹង ខ្ញុំទៅជាប់ជាមួយគាត់ម៉ារយៈដែរ។

ដានី ៖ នៅណា?

ឈុំ ៖ ទៅភ្នំស្រួច។

ដានី ៖ គាត់ទៅភ្នំស្រួច?

ឈុំ ៖ បាទ! គាត់វរៈសេនាតូច គ្រប់គ្រងវរៈសេនាតូចនឹង សមរភូមិឲ្យខ្ញុំទៅប្រហែលកន្លះឆ្នាំ។

ដានី ៖ ទៅនៅជាមួយគាត់?

ឈុំ ៖ ទៅនៅជាមួយគាត់នឹង។

ដានី ៖ ប៉ុននៅម៉ាភ្នំស្រួច គាត់អ្នកធំជាងគេ?

ឈុំ ៖ បងសាន។

ដានី ៖ គាត់ធំជាងគេ?

ឈុំ ៖ បាទ!

ដានី ៖ គាត់កាន់នៅភ្នំស្រួច?

ឈុំ ៖ កាន់នៅភ្នំស្រួច។

ដានី ៖ កែវ ពង្ស?

ឈុំ ៖ កែវ ពង្ស ខាងអមលាំង។

ដានី ៖ ខាងអមលាំង?

ឈុំ ៖ បើខ្មោចតាប៉ានោះ អានឹងកំពង់ឆ្នាំង តែស្លាប់អស់។

ដានី ៖ តាប៉ានឹង គាត់តួនាទីអីដែរ?

ឈុំ ៖ វរៈ។

ដានី ៖ វរៈសេនាតូចដែរ?

ឈុំ ៖ បាទ! អឺ!វវាគ្រប់គ្រង តាមពិតទៅវរៈសេនាធំទៅចុះ តែវាមានម៉ាវរៈសេនាតូចជាប់នៅនឹងខ្លួន តែប៉ុននឹង វាចឹងទេ។

ដានី ៖ អូ! បានន័យថាគាត់ឯករាជ្យ គាត់គ្រប់គ្រង បើតាមសាច់កងទ័ព គ្មាន?

ឈុំ ៖ បាទ! ឯករាជ្យ សាច់កងទ័ពមានម៉ាវរៈសេនាតូចតែប៉ុននឹងទេ។

ដានី ៖ ប្រហែលជា៣០០នាក់នឹងទេ?

ឈុំ ៖ បាទ! មិនដល់ផង ២០០នាក់ជាងប៉ុននឹងឯង ។

ដានី ៖ ចឹងតាសានគាត់នៅភ្នំស្រួច តាប៉ាគាត់នៅ?

ឈុំ ៖ នៅកំពង់ឆ្នាំង តាពង្ស នៅអមលាំង ត្រឹមកំពង់ឆ្នាំងអមលាំងចល័តឆ្លងទៅ ។

ដានី ៖ ហើយតាស៊ីនគាត់?

ឈុំ ៖ តាស៊ីន គាត់សមរភូមិ គាត់គ្រប់គ្រងរួមនឹង ។

ដានី ៖ រួមទៅលើតាប៉ា លើ?

ឈុំ ៖ បាទៗ តាប៉ាទាំងអស់ ។

ដានី ៖ ពូធ្លាប់ទៅនៅជាមួយតាសាន?

ឈុំ ៖ បាទ! ទៅនៅបានប្រហែលកន្លះឆ្នាំដែរ ។

ដានី ៖ នៅបានកន្លះឆ្នាំ ។ ចុះពូរៀបការក្រោយឆ្នាំណា?

ឈុំ ៖ កាលនោះខ្ញុំរៀបតាំងពី៨១ ។

ដានី ៖ រៀបការនៅណា?

ឈុំ ៖ នៅជើងនឹងដែរ នៅយើងដងរែកនឹងដែរ ។

ដានី ៖ ដងរែក ១០០៣?

ឈុំ ៖ ១០០៣ ។

ដានី ៖ ១០០៣ ពីណាគេអ្នកគ្រប់គ្រង?

ឈុំ ៖ នឹងមានតាម៉ុកនឹងហើយ គាត់ទទួលប្រក បើ១០០១អានឹងបានតាស៊ីន សេន ។

ដានី ៖ ១០០១ម្តុំនៅណា?

ឈុំ ៖ អូ! ព្រះវិហារនឹង ។

ដានី ៖ តែឆ្នាំ៨៨ ពូមកខាងក្នុងវិញ?

ឈុំ ៖ បាទ! ឆ្នាំ៨៨ ខ្ញុំមកខាងក្នុងវិញ ។

ដានី ៖ ចុះដល់ពេលយើងមកជាមួយ តាស៊ីន ជាមួយតាសាន ចឹងយើងនៅកន្លែងណាទៅ កន្លែងយើងស្នាក់នៅ?

ឈុំ ៖ នៅឱរ៉ាល់ ចល័តជាប់ ។ តែបងសាន គាត់នៅជាប់សមរភូមិនឹង ។

ដានី ៖ ជាប់សមរភូមិ?

ឈុំ ៖ បាទ! ជាប់សមរភូមិនឹង ។

ដានី ៖ មានផ្ទះ មានអីនៅ?

ឈុំ ៖ អត់ទេ ចល័តដេកនោះម៉ោយប់ ដេកនេះម៉ោយប់ ដូចទន្សាយ ។

ដានី ៖ ដេកផ្ទះគេ?

ឈុំ ៖ អត់មានផ្ទះទេ នៅនឹងព្រៃ។

ដានី ៖ នៅក្នុងព្រៃ?

ឈុំ ៖ បាទ! មានត្រពាំងទឹកអីចឹងទៅ យើងប្រក់កៅស៊ូអីនៅនឹងទៅ កងទ័ពនៅជាប់ជាមួយប្រជាជននៅមុខនឹងទៅ រ៉ៃប្រជាជននឹង ឃោសនាអប់រំប្រជាជននឹង។

ដានី ៖ យើងនៅឆ្ងាយពី?

ឈុំ ៖ បាទ! យើងនៅឆ្ងាយពីកងទ័ព មានគេអូ មានអីសម្រាប់ទាក់ទងមក តាស៊ីននឹង។ តាមព័ត៌មានយើងរ៉ៃខ្ទាំងម៉ោងប៉ុននេះ របួសស្លាប់ត្រង់នេះ រាយការណ៍ជូនតាស៊ីននឹង។

ដានី ៖ កាលជំនាន់៣ឆ្នាំ ដូចតាសានអីនឹង ពូដឹងគាត់នៅណា កាលនឹងពូនៅពោធិ៍ចិនតុង?

ឈុំ ៖ នៅកងទ័ពដែរ សាននៅកងទ័ព១ដូចខ្ញុំចឹង។ ចឹងអត់ដែលបានមកក្រោយអីអត់ទេ។

ដានី ៖ មិនមែនគាត់នៅតំបន់?

ឈុំ ៖ អត់ទេ បងសាន ដូចអត់ដែលមកនៅតំបន់ទេ គាត់នៅតែទ័ពនឹងដែរ។ សាន ទ័ពរហូតតាំងពីនឹងមក។

ដានី ៖ ចុះពូឆ្នាំណា បានចេញពីភ្នំស្រួច ឪរ៉ាល់អី?

ឈុំ ៖ ខ្ញុំទៅបានកន្លះឆ្នាំ ដល់ពេលនេះក៏ខ្ញុំមកនៅសមរភូមិ ហៅមកវិញ ទទួលគ្រួសារខ្ញុំនឹងធ្លាក់ពីលើផ្ទះ។ ដល់ចឹងទៅក៏គេយកទៅដេកពេទ្យខាវអ៊ីដាង កាប់ឈើនៅនឹងម៉ាឆ្នាំកន្លះ។ ដល់ចឹងទៅកាលនឹងខ្ញុំមកកំពង់ឆ្នាំង គ្រួសារនៅដងរ៉ែកនោះទេ ទាំងអស់ទាំងគ្នា កងទ័ពដែលមកនឹង។ ដល់ពេលមកចឹងមក ក៏បានប៉ុន្មានថ្ងៃ ខ្ញុំឆ្លងទន្លេមកបានប្រហែលម៉ាអាទិត្យ គ្រួសារធ្លាក់ពីលើផ្ទះនោះ។ ត្រឡប់ខាងជំរំ ខាងបារាំងដឹកទៅខាវអ៊ីដាង។ ដល់ចឹងខ្ញុំមិនដឹងឡើងមកតាមណារួច ឥឡូវប្រថុយត្រឡប់ទៅវិញឆ្លងទន្លេ ចឹងយើងមិនហ៊ានទៅ។ ចឹងចេះតែនៅធ្វើការសមរភូមិ......(ស្តាប់មិនបាន) ។ ដល់ពេលនេះមក តាម៉ុកគាត់ឲ្យដឹកប្រពន្ធកូនអ្នកដែលមកធ្វើការនៅកំពង់ឆ្នាំងដឹកតាមដីថៃមកចុះយើងនៅ....(ស្តាប់មិនបាន) ស្រុកសំឡូតនេះ។ ហើយបានសមរភូមិឲ្យខ្ញុំឡើងមក ខ្ញុំសុំគេនៅ ក្រោយលែងទៅមុខ។

ដានី ៖ ឆ្នាំណា?

ឈុំ ៖ តាំងពីមុន៩៣នោះ។

ដានី ៖ ចឹងនៅក្រោយរហូត?

ឈុំ ៖ បាទ! នៅក្រោយរហូត។

ដានី ៖ កាលឆ្នាំណា បានពូមកនៅនេះ?

ឈុំ : នេះមកនៅនេះឆ្នាំ២០០០ ។ តាមពិតខ្ញុំមកនៅភូមិចាស់នោះ មកតាំងពី៩៥ ។

ដានី : ភូមិចាស់នៅណា?

ឈុំ : ភូមិចាស់នៅ៦គីឡូ នៅជើងភ្នំ ។

ដានី : គេហៅអី?

ឈុំ : ស៊ឹង ។

ដានី : គេហៅភូមិអី?

ឈុំ : បាទ! ភូមិចំការជ្រៃ ។

ដានី : ចំការជ្រៃដែរ?

ឈុំ : ចំការជ្រៃ ចឹងភូមិទាំងអស់ប៉ុន្មានភូមិ យកឈ្មោះពីនឹងទេ ចំការជ្រៃជើង ចំការជ្រៃត្បូង ក្រាំងរនៀង យកឈ្មោះពីភូមិចាស់ ។

ដានី : មុនដំបូង៩៥នៅនោះ?

ឈុំ : បាទ! ៩៥នៅនោះ ។

ដានី : ម៉េចបានផ្លាស់មកនៅនឹង?

ឈុំ : មូលហេតុ គ្រាន់ថាវាពិបាកត្រង់រឿងផ្លូវទៅមក តែខែវស្សាគឹអត់មានចេញចូលទៅណាបានទេ ដីវាស្អិត ហើយវាគ្មានផ្លូវ ។

ដានី : ប៉ុន្តែមុនឆ្នាំ៩៥ ពូនៅខាងសំឡូត?

ឈុំ : សំឡូត បាទ!សំឡូត ។

ដានី : ម៉េចបានផ្លាស់មកពីសំឡូត មកនៅខាងនេះ?

ឈុំ : អានឹងវាចេះទេ កាលនឹង....គណៈប្រកនឹង ឯកឧត្តម មាស មុតនឹង គាត់ក្តាប់សភាពការណ៍ពីខាងយើងផ្តល់ឲ្យ ហើយបានគាត់ដក ។ ដកនេះ ដកសម្រាប់ទទួលគ្រាន់ស្នាក់ ។ ពីដើមយើងមានកម្លាំងនៅថ្មដារ យើងមានកម្លាំងនៅសំព័រ ដល់ចឹងចន្លោះនេះវាដាច់ ។ ចឹងគាត់ឲ្យខ្ញុំយក៣០គ្រួសារមកដាក់នៅភូមិចាស់ចេះ ។ ដាក់នឹងក៏ត្រៀមទទួលកម្លាំងពីថ្ងៃ៥ថ្ងៃ៦ ។ ចឹងប្រពន្ធកូនដែលកិច្ចព្រមព្រៀងឆ្នាំ៩៣ កង៍ទ័ពដែលនៅក្នុងនោះ យកប្រពន្ធកូនទៅតាម ហើយកាលនោះមេខ្មែរក្រហមចែកកាំបិត ចែកពូថៅ ចែកចបអីឲ្យ ។ ដល់យកទៅតាម ដល់ថ្ងៃ៥ថ្ងៃ៦នឹង សភាពការណ៍ប្រែប្រួល ដកប្រពន្ធកូនមកវិញ នៅនឹងបណ្តោយ ។

ដានី : ចុះពូ ដល់ពេលយើងនៅសមរភូមិក្រោយ យើងលែងទៅសមរភូមិមុខ ហើយយើងនៅក្រោយ យើងធ្វើអីទៀត ពូទទួលការអីដែរ?

ឈុំ : ទទួលមេភូមិ ទទួលរៀបរយ..... ។

ដានី ៖ ភូមិណា ភូមិចំការជ្រៃ?

ឈុំ ៖ ភូមិចំការជ្រៃ ។

ដានី ៖ ចុះឥឡូវពូនៅក្នុងភូមិណា?

ឈុំ ៖ ខ្ញុំបាទ នៅជាប់ក្រុមប្រឹក្សានេះទេ ជាមួយគាសេងយើង ។

ដានី ៖ អូ! ឥឡូវនៅក្រុមប្រឹក្សាឃុំ?

ឈុំ ៖ បាទៗ ។

ដានី ៖ ក្រុមប្រឹក្សាឃុំតាំងពីឆ្នាំណា?

ឈុំ ៖ ក្នុង២០០០មើលបោះឆ្នោត ២០០១ ២០០២មិនដឹងទេ ។

ដានី ៖ ពីមុនមកធ្វើអី?

ឈុំ ៖ ពីមុនមកអត់មានធ្វើអីទេ ខ្ញុំនៅគ្រប់គ្រងប្រជាជន៣០-៤០គ្រួសារ ។

ដានី ៖ មេភូមិដែរអត់ទេ?

ឈុំ ៖ បាទ! ធ្វើភូមិ ។

ដានី ៖ មក២០០២មក បានធ្វើ?

ឈុំ ៖ បាទ! ក្រុមប្រឹក្សា ។

ដានី ៖ ចុះពូឮព័ត៌មានទាក់ទងពី តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ហើយដូចករណី ០០១ ០០២ ។ ពូដែលឮព័ត៌មាននឹងដែរ?

ឈុំ ៖ ឮដែរ ស្តាប់ដែរ ។

ដានី ៖ ពូស្តាប់ឮយ៉ាងម៉េចខ្លះដែរ?

ឈុំ ៖ ស្តាប់បានតិចៗ មិនចប់ចុងចប់ដើមទេ ហើយនឹងបានមើលកាសែត ស្វែងរកការពិតពីមុនមក ដូចបានកាសែតនឹងមួយចេះតែមើលទៅ ។ ចឹងអារឿងការកាត់ទោសអីៗ បើនិយាយទៅអានឹងសម្រាប់ខាងក្រោមដឹងតែពីធ្វើទេ អារឿងកិច្ចការផ្សារមនុស្សវាអត់ដឹងទេ ។ ព្រោះយើងវាដឹកនាំថ្នាក់ក្រោម ។

ដានី ៖ ប៉ុន្តែពូយល់ឃើញម៉េចដែរ ដូចថា.......(ស្តាប់មិនបាន សម្លេងរំខានពីម៉ាស៊ីន)?

ឈុំ ៖ ទេ! បើតាមការយល់ដឹង អានឹងអត់មានយល់ខុសអី ធ្វើម៉េចអានឹងតាមផ្លូវច្បាប់ វាទៅចឹងទៅហើយ ។

ដានី ៖ ប៉ុន្តែ ពូគិតថាការបង្កើតតុលាការនឹង វាត្រឹមត្រូវដែរ ឬក៏មិនត្រឹមត្រូវទេ?

ឈុំ ៖ អានឹងតាមពិតទៅវា បើគិតទៅវាជាការត្រឹមត្រូវហើយ ព្រោះដើម្បីបញ្ចប់រឿងទុក្ខសោកពីមុនមកយ៉ាងម៉េចៗ ។ ដូច្នេះ បង្កើតតុលាការនឹងទៅ ចឹងមនុស្សយើង យល់ដឹងពីច្បាប់ទម្លាប់ ។ ចឹងការធ្វើអីមួយត្រូវតែគិតពីបញ្ហាខុស បញ្ហាត្រូវ ។ វាពិបាកចឹង ។

ដានី ៖ បាទ! ខ្ញុំដូចជាអស់សំនួរអី ត្រូវសួរទាំពូទៀតហើយ ចឹងពូមានអីចង់បន្ថែម នូវអ្វីដែលខ្ញុំអត់បានសួរទេ?

ឈុំ ៖ ដូចគ្មានស្អី រឿងរ៉ាវដូចខ្ញុំបានជម្រាបហូរហែលខ្លះ មកចឹង ។

ដានី ៖ បាទ! ចឹងអរគុណពូច្រើន ដែលបានចំណាយពេលផ្តល់បទសម្ភាសន៍ជាមួយខ្ញុំ អរគុណពូច្រើន ។

«ចប់»